# ជំពូកទី ៦
# ការចូលរួមពីសាធារណៈជន

Draft

# ជំពូកទី ៦
# ការចូលរួមពីសាធារណៈជន

## ៦.១ សេចក្តីផ្តើម

ការពិគ្រោះយោបល់ ឬស្ទង់មតិជាសាធារណៈនេះជាផ្នែកមួយដ៏សំខាន់ នៃការសិក្សាវាយតម្លៃទៅលើផលប៉ះពាល់បរិស្ថាន និងសង្គម ព្រោះវាជាការសិក្សាពីទស្សនៈ និងយោបល់របស់បណ្តាអ្នកពាក់ព័ន្ធទាំងឡាយក្នុងតំបន់សិក្សា។ ដោយហេតុថាគម្រោងវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** អាចនឹងធ្វើឲ្យមាននូវហេតុប៉ះពាល់បរិស្ថាន និងសង្គម ទៅដល់សហគមន៍មូលដ្ឋាន និងក្រុមហ៊ុននានាដែលស្ថិតនៅជុំវិញតំបន់សិក្សា។ ក្រុមហ៊ុន ហ្គ្រីន អ៊ិនវ៉ាយ រ៉ិន មិន គ្រុប **(GREEN ENVIRONMENT GROUP CO.,LTD.)** ដែលជាក្រុមហ៊ុនសិក្សាទៅលើហេតុប៉ះពាល់បរិស្ថាន និងសង្គម បានធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយផ្អែកទៅលើច្បាប់ និងបទបញ្ញត្តិនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការរៀបចំជាការស្ទង់មតិសាធារណៈដោយធ្វើការអញ្ជើញអ្នកពាក់ព័ន្ធឲ្យចូលរួម ដូចជាអាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធនានា ដើម្បីស្វែងយល់ពីទស្សនៈរបស់អ្នកពាក់ព័ន្ធទាំងនោះ ដែលជាកត្តាមួយអាចជួយសម្រាលនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

## ៦.២ គោលបំណង

ចំពោះគោលបំណងនៃការពិគ្រោះយោបល់ ឬការស្ទង់មតិជាសាធារណៈនេះគឺ៖

- ធ្វើការស្ទាបស្ទង់មតិពីបណ្តាអ្នកពាក់ព័ន្ធនានាទៅលើតំបន់សិក្សាស្រាវជ្រាវ
- ស្វែងយល់ពីបញ្ហានានាដែលអាចនឹងបង្កើតឡើងដោយសារគម្រោង
- ធ្វើការស្ទាបស្ទង់ និងស្នើសុំសំណូមពរពីអ្នកពាក់ព័ន្ធ និងអាជ្ញាធរភូមិ ឃុំក្នុងមូលដ្ឋានចំពោះគម្រោង។

## ៦.៣ វិធីសាស្ត្រ និងតំបន់គោលដៅ

ដើម្បីឲ្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញមានភាពត្រឹមត្រូវ និងច្បាស់លាស់នោះ ក្រុមការងាររបស់ក្រុមហ៊ុន ហ្គ្រីនអ៊ិនវ៉ាយរិនមិន គ្រុប **(GREEN ENVIRONMENT GROUP CO.,LTD.)** បានប្រើប្រាស់វិធីសាស្ត្រ ការពិគ្រោះយោបល់ និងការសម្ភាសន៍ក្នុងគោលបំណងដើម្បីស្រង់ព័ត៌មាន និងសុំយោបល់ពីអ្នកពាក់ព័ន្ធនានា។ ការសម្ភាសន៍ត្រូវបានធ្វើដោយផ្តោតទៅលើក្រុមគោលដៅដូចជា៖

+ អាជ្ញាធរដែនដី
- អាជ្ញាធរខេត្ត ព្រះវិហារ
- អាជ្ញាធរស្រុកជ័យសែន
- អាជ្ញាធរឃុំស្អាង
- អាជ្ញាធរភូមិស្អាង
- អាជ្ញាធរភូមិគោក
- អាជ្ញាធរឃុំតស៊ូ
- អាជ្ញាធរភូមិតស៊ូ
- អាជ្ញាធរភូមិសំពោង

- អាជ្ញាធរឃុំពុទ្រា
- អាជ្ញាធរភូមិពុទ្រា
- អាជ្ញាធរភូមិបរ

+ មន្ទីរ និងស្ថាប័នជំនាញពាក់ព័ន្ធ

- មន្ទីរបរិស្ថាន ខេត្តព្រះវិហារ
- មន្ទីរកសិកម្ម ខេត្តព្រះវិហារ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ
- មន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រះវិហារ
- មន្ទីររ៉ែ និងថាមពល ខេត្តព្រះវិហារ
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ
- មន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តព្រះវិហារ
- មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តព្រះវិហារ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះវិហារ
- ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ
- ខណ្ឌរដ្ឋបាលជលផលព្រះវិហារ

## ៦.៤ លទ្ធផលនៃការពិគ្រោះយោបល់

### ៦.៤.១ អាជ្ញាធរដែនដី

#### ក. អាជ្ញាធរខេត្តព្រះវិហារ

កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរខេត្តព្រះវិហារ នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៥ វេលាម៉ោង ២:៣០ នាទីរសៀល នៅសាលាខេត្តព្រះវិហារ។ ក្រុមការងាររបស់ក្រសួងបរិស្ថានដែលដឹកនាំដោយ ឯកឧត្តម ឯ វុឌ្ឍី ទីប្រឹក្សាក្រសួងបរិស្ថាន បានជួបប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធក្រោមការដឹកនាំរបស់ឯកឧត្តម ស៊ូ សិរី អភិបាលរងខេត្តព្រះវិហារ ជាប្រធានអង្គប្រជុំ។

ឯកឧត្តម ស៊ូ សិរី អភិបាលរងខេត្តមានប្រសាសន៍ថា ឯកឧត្តមយល់ស្របនឹងគម្រោងវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង ពីព្រោះគម្រោងវិនិយោគនេះបានជួយអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើនថែមមួយកម្រិតទៀត។ ឯកឧត្តមឯកភាពនូវការលើកឡើងរបស់លោកអភិបាលស្រុកជ័យសែន ពីការរក្សាទុកដី ១០% ហើយដី ១០% ស្រុក បានចុះទៅកំណត់ព្រំ និងវាស់វែង ក្រោយវាស់វែងរួចខេត្តបានផ្ទេរទៅឲ្យស្រុក ស្រុកបានផ្ទេរទៅឲ្យឃុំសម្រាប់ទុកជូនគ្រួសារក្រីក្រ អ្នកទើបរៀបការរួច។ កន្លងមកក្រុមហ៊ុន បានរក្សាទុកផ្ទៃដីព្រៃពី ៥០ ទៅ ៦០ម៉ែត្រ សម្រាប់ជាព្រំការពារដីរបស់ក្រុមហ៊ុន។

#### ខ. អាជ្ញាធរស្រុកជ័យសែន

ការពិគ្រោះយោបល់ជាមួយនឹង លោក ថោង សាគឿន អភិបាលនៃគណៈអភិបាលស្រុក ជ័យសែន ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង០៩:៤៣ នាទីព្រឹក នៅសាលាស្រុកជ័យសែន ខេត្តព្រះវិហារ។

លោកអភិបាលស្រុកមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបអំពីវត្តមានគម្រោងវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (**Heng Non (Cambodia) International**

**Company Limited)** ពីមុនមក។ លោកឯកភាពនឹងគម្រោងវិនិយោគ របស់ក្រុមហ៊ុនខាងលើនេះ ពីព្រោះគម្រោងវិនិយោគនេះធ្វើឲ្យសេដ្ឋកិច្ចក្នុងតំបន់មានការរីកចម្រើន ។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋចំនួន ០៣ ឃុំគឺ ឃុំតស៊ូ ឃុំស្អាង និងឃុំពុទ្រា ប៉ុន្តែត្រូវបានក្រុមយុវជនស្ម័គ្រចិត្ត សម្តេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិរួចចំនួន ២ឃុំគឺ ឃុំតស៊ូ និងឃុំស្អាង ចំណែកឃុំពុទ្រាមិនបានវាស់នូវឡើយទេ។

ផលប្រយោជន៍

- ប្រជាពលរដ្ឋដែលមានដីអាចដាំអំពៅលក់ឲ្យក្រុមហ៊ុនបាន ក្នុងករណីក្រុមហ៊ុនមានគោលនយោបាយច្បាស់លាស់ជាមួយប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋមានការងារធ្វើ
- ប្រជាពលរដ្ឋមានជីវភាពរីកចម្រើន។

សំណូមពរ

- សូមឲ្យក្រុមហ៊ុន ជួយសាងសង់ស្ពាន និងផ្លូវតភ្ជាប់ពីផ្លូវមេរបស់ក្រុមហ៊ុនទៅកាន់ទីរួមស្រុកជ័យសែន
- សូមឲ្យក្រុមហ៊ុនទទួលទិញដំណាំអំពៅរបស់ប្រជាពលរដ្ឋដែលនៅក្រៅតំបន់គម្រោង
- សូមឲ្យអភិបាលខេត្តបន្តបង្កើតក្រុមយុទ្ធនាការណ៍វាស់វែងដីធ្លីដែលនៅសល់ក្នុងតំបន់គម្រោង។

គ. អាជ្ញាធរឃុំស្អាង (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក មាស សិត មេឃុំស្អាង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង ១១:១០ នាទីព្រឹក នៅសាលាឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ ។

លោកធ្លាប់បានជ្រាបអំពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** តាមរយៈការចុះសិក្សាជាមួយគណៈកម្មការខេត្ត និងសុរិយោដីខេត្តព្រះវិហារ អំពីផលប៉ះពាល់។

លោកមេឃុំមានការយល់ស្របនឹងគម្រោងវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** ព្រោះគម្រោងនេះជួយអភិវឌ្ឍន៍ភូមិ ឃុំ។

ផលប៉ះពាល់

- ប៉ះពាល់ភូមិស្អាង និងភូមិគោក ក្នុងនោះប៉ះពល់ទៅលើដីស្រែចម្ការដែលមានប្រមាណ ១៥០គ្រួសារ ប៉ុន្តែភូមិស្អាង ក្រុមយុវជនស្ម័គ្រចិត្ត សម្តេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋរួចរាល់ហើយ។

ផលប្រយោជន៍

- មានហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា សាលារៀន មន្ទីរពេទ្យ ផ្លូវ ស្ពាន អណ្តូងទឹក
- ប្រជាពលរដ្ឋមានការងារធ្វើ និងកាត់បន្ថយចំណាកស្រុក
- កាត់បន្ថយភាពក្រីក្រ
- សេដ្ឋកិច្ចគ្រួសារកើនឡើង។



Draft

សំណូមពរ

- សូមឲ្យក្រុមហ៊ុនកាត់ដីដែលពាក់ពន្ធរបស់ប្រជាពលរដ្ឋចេញពីទីតាំងដីវិនិយោគ
- សូមឲ្យក្រុមហ៊ុនជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរ ពេទ្យ ស្ពាន អណ្តូងទឹក
- សូមឲ្យបន្តវាស់វែងដីនៅក្នុងភូមិគោក
- សូមឲ្យក្រុមហ៊ុនជួយដីស្រែនៅក្នុងភូមិ
- សូមឲ្យក្រុមហ៊ុនសាងសង់ សាលាឃុំថ្មី និងបណ្តាញអគ្គិសនីនៅសាលាឃុំ។

• អាជ្ញាធរឃុំស្អាង(ការពិគ្រោះយោបល់លើកទី២)

នៅក្នុងឃុំស្អាងមានភូមិ០២ដែលមានការពាក់ព័ន្ធនឹងទីតាំងគម្រោង គឺភូមិស្អាង និងភូមិគោក។ មកដល់បច្ចុប្បន្នក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ធ្វើការដោះស្រាយស្ទើតែរួចរាល់អស់ហើយ។ លោកមេឃុំមិនទាន់ក្តាប់បាននូវចំនួនគ្រួសារ និងទំហំផ្ទៃដីនៅឡើយទេ។

ឃ. អាជ្ញាធរភូមិស្អាង(ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោកស្រី កៅ គឹមជី មេភូមិស្អាង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង ១១:៣០ នាទីព្រឹក នៅផ្ទះមេភូមិស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ ។

លោកស្រីធ្លាប់បានជ្រាបអំពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំ អាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** ពីមុនមក ហើយលោកស្រីពុំជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ ព្រោះគម្រោងអភិវឌ្ឍន៍ខាងលើនេះជួយ ភូមិ ឃុំ រីកចម្រើន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ ភូមិស្អាង ប៉ុន្តែក្រុមយុវជនស្ម័គ្រ សម្តេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋរួចរាល់ហើយ។

ផលប្រយោជន៍

- ប្រជាពលរដ្ឋមានការងារធ្វើ
- ជីវភាពប្រជាពលរដ្ឋធូរធារ
- កាត់បន្ថយចំណាកស្រុក។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា អណ្តូងទឹក សាលារៀន ផ្លូវលំ ស្ពារលូ។
- សូមឲ្យក្រុមហ៊ុនជួយចាក់ដីនៅសាលាធទានក្នុងភូមិកុំឲ្យលិចទឹក។

• អាជ្ញាធរមេភូមិស្អាង (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោកស្រី កៅ គឹមជី មេភូមិស្អាង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១១:៤០ នាទី នៅផ្ទះលោកស្រីមេភូមិ។

ផលប៉ះពាល់

- នៅក្នុងភូមិស្អាងមានដីប៉ះពាល់ជាមួយក្រុមហ៊ុន គឺមានតិចតួចប៉ុណ្ណោះ។ អ្នកស្រីមេភូមិមិនអាចក្តាប់ព័ត៌មានពីចំនួនគ្រួសារ និងទំហំដីរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ជាមួយក្រុមហ៊ុនទេ
- បច្ចុប្បន្នក្រុមហ៊ុនមិនទាន់បានអភិវឌ្ឍន៍ដល់ភូមិ ឃុំដូចជា ផ្លូវ សាលា រៀន អណ្តូងទឹកនៅឡើយ។

ផលប្រយោជន៍

- ផ្តល់ការងារដល់ប្រជាពលរដ្ឋ
- ការកើតឡើងប្រាក់ចំណូលសម្រាប់គ្រួសារ

សំណូមពរ

- សុំឲ្យក្រុមហ៊ុនជួយសាងសង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ សាលារៀន អណ្តូងទឹក និងវត្តអារាម។

ង. អាជ្ញាធរភូមិគោក(ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក មាន ម៉ៅ មេភូមិគោក ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង០៨:៤០ នាទីព្រឹក នៅផ្ទះមេភូមិគោក ស្រុកជ័យសែន ខេត្តព្រះវិហារ ។

លោកធ្លាប់បានជ្រាបអំពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំ អំពៅ និងអាកាស្យា របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** នេះពីមុនមក។

លោកពុំជំទាស់និងគម្រោងវិនិយោគខាងលើនេះទេ ព្រោះគម្រោងខាងលើនឹងជួយអភិវឌ្ឍន៍ ភូមិ ឃុំ ឲ្យមានភាពរីកចម្រើន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ ភូមិចំនួន ១១០គ្រួសារ

ផលប្រយោជន៍

- ប្រជាពលរដ្ឋមានការងារធ្វើ
- ប្រាក់ចំណូលប្រជាពលរដ្ឋមានការកើនឡើង
- កាត់បន្ថយចំណាកស្រុក។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនដោះស្រាយដីស្រែចម្ការដែលប៉ះពាល់របស់ប្រជាពលរដ្ឋភូមិគោក ក្នុងករណីដែលក្រុមហ៊ុនធ្វើការឈូសឆាយទៅដល់
- សូមឲ្យក្រុមហ៊ុនសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវលំ អណ្តូងទឹក សាលារៀន មន្ទីរពេទ្យ

• អាជ្ញាធរភូមិគោក (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក ម៉ី ហន មេភូមិគោក ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១២:២៤ នាទី នៅផ្ទះលោកមេភូមិគោក។

ផលប៉ះពាល់

- មិនប៉ះពាល់ដល់ដីក្នុងឃុំស្អាងទេ ប៉ុន្តែប៉ះពាល់ដល់ដីនៅឃុំតស៊ូ ដែលជាកម្មសិទ្ធរបស់ប្រជាពលរដ្ឋឃុំស្អាង ភូមិគោក
- ធ្លាប់មានការឈូសឆាយប៉ះពាល់ដីប្រជាពលរដ្ឋនៅក្នុងភូមិគោក ដែលមានទីតាំងក្នុងឃុំតស៊ូ ប៉ុន្តែលោកមេភូមិមិនទាន់ទទួលបានព័ត៌មានថាមានប៉ុន្មានគ្រួសារ និងទំហំដីប៉ុន្មាននៅឡើយទេ
- នៅក្នុងភូមិគោក ក្រុមយុវជនស្ម័គ្រចិត្តរបស់សម្តេច តេ ជោ មិនទាន់បានវាស់វែងនៅឡើយទេ

សំណូមពរ

- សូមឲ្យក្រុមហ៊ុន ទុកដីដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋក្នុងភូមិគោក ដោយកុំឲ្យមានការឈូសឆាយ។



Draft

ច. អាជ្ញាធរឃុំពុទ្រា (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក ជុំ គៀង មេឃុំពុទ្រា ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង ០២:៣០ នាទីរសៀល នៅសាលាឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ។

លោកបានជ្រាបវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអំពៅ និងអាកាស្យា របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)**។ លោកមេឃុំយល់ស្របនឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុននេះ ព្រោះគម្រោងនេះស្របតាមគោលនយោបាយចាស់សកម្មភាពថ្មីរបស់រាជរដ្ឋាភិបាល និង ជួយអភិវឌ្ឍន៍ ភូមិ ឃុំឲ្យមានការរីកចម្រើន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋក្នុងភូមិពុទ្រា ភូមិបរ និងភូមិក្រាំដែលជាឧបសម្ព័ន្ធរបស់ភូមិបរ
- ប៉ះពាល់ដីដែលលែងសត្វ។

ផលប្រយោជន៍

- ប្រជាពលរដ្ឋមានការងារធ្វើ និងកាត់បន្ថយចំណាកស្រុក
- កាត់បន្ថយភាពក្រីក្រ
- មានហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវ សាលារៀន អណ្តូងទឹក មន្ទីរពេទ្យ។ល។
- សេដ្ឋកិច្ចជាតិមានការកើនឡើង។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនជួយកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំដូចជា ស្ពាន ផ្លូវ សាលារៀន មន្ទីរពេទ្យ និងជាពិសេសសូមឲ្យក្រុមហ៊ុនជួយសាងសង់ ស្ពានអូរវែងដួល និងសាលារៀនៅក្នុងភូមិបរ។
- សូមឲ្យក្រុមហ៊ុនសហការណ៍ល្អជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន
- សូមឲ្យក្រុមហ៊ុនកាត់ចេញនូវដីដែលប៉ះពាល់ច្រើន ជាមួយប្រជាពលរដ្ឋ
- បើក្រុមហ៊ុនសិក្សា បង្ហាញថាផលប៉ះពាល់ច្រើន ហើយដីក្រុមហ៊ុននូវសល់តិច សូមឲ្យក្រុមហ៊ុនកាត់ជូនប្រជាពលរដ្ឋ។

- អាជ្ញាធរឃុំពុទ្រា (ការពិគ្រោះយោបល់លើកទី២)

នៅក្នុងឃុំពុទ្រា ក្រុមហ៊ុនមិនទាន់ធ្វើការឈូសឆាយមកដល់នៅឡើយទេ។ លោកមេឃុំមានប្រសាសន៍ថាភូមិដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនគឺ ភូមិបរ និងភូមិពុទ្រា ហើយបច្ចុប្បន្ននេះគឺក្រុមហ៊ុនបានសាងសង់ផ្លូវកាត់ភូមិក្នុងភូមិសាស្ត្រភូមិបរ។

ក្រុមហ៊ុនបានវាស់វែងលើដីបម្រុងទុកសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅក្នុងឃុំរួចហើយ ដែលមានទំហំប្រហែល ១០០ ហិកតា។

ឆ. អាជ្ញាធរភូមិបរ (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក សុក ភាព មេភូមិបរ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង០២:៣០ នាទី នៅសាលាឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ។ លោកធ្លាប់បានដឹងអំពីវត្តមានគម្រោងវិនិយោគរបស់ក្រុមហ៊ុន ហេង ណុង ពីមុនមក។ លោកពុំជំទាស់នឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុនខាងលើនេះទេ ពីព្រោះការអភិវឌ្ឍន៍ធ្វើឲ្យ ភូមិ ឃុំ មានភាពរីកចម្រើន។



Draft

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ នៅក្នុងភូមិបរ និងភូមិក្រាំងដែលជាឧបសម្ព័ន្ធរបស់ភូមិបរ

ផលប្រយោជន៍

- ផ្តល់ការងារដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- កាត់បន្ថយភាពក្រីក្រ
- កាត់បន្ថយចំណាកស្រុក
- មានកំណើនសេដ្ឋកិច្ចក្នុងមូលដ្ឋាន

សំណូមពរ

- សូមឲ្យក្រុមហ៊ុនជួយកសាងស្ពានឆ្លងកាត់អូរវែងល
- សូមឲ្យក្រុមហ៊ុនជួយសាងសង់ សាលារៀននៅក្នុងភូមិបរ
- សូមឲ្យក្រុមហ៊ុនកាត់ចេញនូវដីស្រែចម្ការដែលប៉ះពាល់ជាមួយប្រជាពលរដ្ឋ
- សូមឲ្យក្រុមហ៊ុនសហការណ៍ល្អជាមួយប្រជាពលរដ្ឋ និងអជ្ញាធរ
- បើសិនក្រុមហ៊ុនសិក្សាឃើញថាផលប៉ះពាល់ដីស្រែចម្ការប្រជាពលរដ្ឋច្រើន ហើយដីក្រុមហ៊ុននៅសល់តិច សូមឲ្យក្រុមហ៊ុនកាត់ជូនប្រជាពលរដ្ឋ។

• អាជ្ញាធរភូមិបរ (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក សុក ភាព មេភូមិបរ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១២:២៤ នាទី នៅសាលាឃុំពុទ្រា។

ផលប៉ះពាល់

- នៅក្នុងភូមិបរ ក្រុមហ៊ុនកំពុងតែសាងសង់ផ្លូវកាត់ភូមិហើយក៏បានដោះស្រាយ ជាមួយប្រជាពលរដ្ឋ ដែលមានការប៉ះពាល់ជាមួយផ្លូវដែលកំពុងសាងសង់។ ចំពោះដីដែលមានបណ្ណ័កម្មសិទ្ធ ក្រុមហ៊ុនបានទូទាត់ជាសំណងជូន ប៉ុន្តែបើដីនោះមិនមានបណ្ណ័កម្មសិទ្ធទេនិងចាត់ទុកជាដីរដ្ឋ
- បច្ចុប្បន្នប្រជាពលរដ្ឋមានការព្រួយបារម្ភដែលក្រុមហ៊ុន អាចឈូសឆាយប៉ះពាល់ដល់ដីរបស់គាត់។

ផលប្រយោជន៍

- ផ្តល់ការងារជូនប្រជាពលរដ្ឋ និងបានសាងសង់ផ្លូវក្នុងភូមិ

សំណូមពរ

- សូមឲ្យក្រុមហ៊ុនជួយសាងសង់ផ្លូវនៅក្នុងភូមិ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ

ជ. អាជ្ញាធរភូមិពុទ្រា (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក យុត ចេន មេភូមិពុទ្រា ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ ម៉ោង១០:២៥ នាទី នៅសាលាឃុំពុទ្រា ស្រុកជ័យសែន ខេត្តព្រះវិហារ ។

លោកធ្លាប់បានជ្រាបពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំ អាកាស្យា និង អំពៅរបស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** ពីមុនមក។

លោកពុំជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ ព្រោះគម្រោងនេះនិងជួយអភិវឌ្ឍន៍ ភូមិ ឃុំ ឲ្យមានភាពរីកចម្រើន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋនៅក្នុងភូមិពុទ្រា ចំនួន ១០១គ្រួសារ ដែលក្នុងនោះ ផ្ទៃដីស្រែសរុប ២៨២ហិកតា និងផ្ទៃដីចម្ការសរុប ៣៣៨ហិកតា។

ផលប្រយោជន៍

- ប្រជាពលរដ្ឋក្នុងមូលដ្ឋានមានការងារធ្វើ
- ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមានការកើនឡើង
- កាត់បន្ថយចំណាលស្រុក។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋជាមុនសិន មុននឹងដំណើរកោរឈូសឆាយ
- សូមឲ្យក្រុមហ៊ុនជួយក៏សាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវលំ សាលារៀន មន្ទីរពេទ្យ អណ្តូង ទឹក។

• អាជ្ញាធរមេភូមិពុទ្រា (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក យុត ចេន មេភូមិពុទ្រា ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១៥:២០ នាទី នៅសាលាឃុំពុទ្រា។ លោកបានមានប្រសាសន៍ថា ចំពោះនៅក្នុងភូមិពុទ្រា មិនទាន់មានផលប៉ះពាល់អ្វីជាមួយក្រុមហ៊ុនទេ ដោយក្រុមហ៊ុនធ្លាប់ចុះសិក្សាដល់ទីតាំងផ្ទាល់ ទោះបីជាគ្មានបញ្ហាអ្វីនៅឡើយ តែវាអាចប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ។

ផលប្រយោជន៍

- បង្កើតការងារសម្រាប់អ្នកភូមិ និងបង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋពេលបម្រើការក្នុងក្រុមហ៊ុន
- កាត់បន្ថយចំណាកស្រុក

សំណូមពរ

- សូមឲ្យក្រុមហ៊ុនសហការជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ ជួយធ្វើបណ្ណ័កម្មសិទ្ធដីធ្លីជូនប្រជាពលរដ្ឋ ដែលមានដីពាក់ព័ន្ធនិងក្រុមហ៊ុន។

ឈ. អាជ្ញាធរឃុំតស៊ូ (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក ព្រំ កើន មេឃុំតស៊ូ បានធ្វើឡើងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១១:១៥ នាទី នៅសាលាឃុំតស៊ូ។

លោកមេឃុំធ្លាប់បានជ្រាបពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអំពៅ និងអាកាស្យា របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)**។ លោកមេឃុំយល់ស្របនឹងគម្រោងវិនិយោគ ព្រោះក្រុមហ៊ុនបានអភិវឌ្ឍន៍ ភូមិ ឃុំ និងមានកំណើន សេដ្ឋកិច្ចនៅក្នុងតំបន់។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋរបស់ភូមិតស៊ូ និងភូមិសំពេង ប៉ុន្តែដីដែលប៉ះពាល់ក្រុមហ៊ុនគឺក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋរួចហើយ។

ផលប្រយោជន៍

- ប្រជាពលលរដ្ឋមានការងារធ្វើ និងកាត់បន្ថយចំណាលស្រុក
- សេដ្ឋកិច្ចគ្រួសារមានការកើនឡើង
- កាត់បន្ថយភាពក្រីក្រ

សំណូមពរ

- សូមឲ្យក្រុមហ៊ុនសហការល្អជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរក្នុងតំបន់
- សូមឲ្យក្រុមហ៊ុនកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា ផ្លូវ សាលារៀន មន្ទីរពេទ្យ អណ្តូងទឹក វត្តអារាម។ល។

• អាជ្ញាធរឃុំតស៊ូ (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក ព្រំ កើន មេឃុំតស៊ូ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ម៉ោង០១:០០ នាទីរសៀល នៅខេត្តព្រះវិហារ។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែ ចម្ការ របស់ភូមិតស៊ូ ភូមិសំពេង និងភូមិថ្មី ប៉ុន្តែលោកមិនទាន់ក្តាប់បាននូវចំនួនគ្រួសារ និងទំហំផ្ទៃដីនៅឡើយទេ
- លោកមេឃុំកំពុងតែរងចាំដំណោះស្រាយពីថ្នាក់ស្រុក ថ្នាក់ខេត្ត និងស្ថាប័នជំនាញពាក់ព័ន្ធ

៣. អាជ្ញាធរភូមិសំពេង (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក ព្រំ សោន ក្រុមប្រឹក្សាឃុំតស៊ូតំណាងភូមិសំពេង បានធ្វើឡើងកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១១:៣៥ នាទី នៅផ្ទះក្រុមប្រឹក្សាឃុំតស៊ូតំណាង ភូមិសំពេង។

លោកមេឃុំធ្លាប់បានជ្រាបពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអំពៅ និងអាកាស្យារបស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** នេះពីមុនមក។ លោកពុំជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ ព្រោះក្រុមហ៊ុននិងជួយអភិវឌ្ឍន៍ ភូមិ ឃុំ ឲ្យមានការរីកចម្រើន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋរបស់ភូមិសំពេង ប្រហែល ៧០គ្រួសារ ប៉ុន្តែក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោ បានចុះវាស់វែងដីធ្លី និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋភូមិសំពេង រួចរាល់ហើយ។

ផលប្រយោជន៍

- ប្រជាពលលរដ្ឋមានការងារធ្វើ
- ប្រាក់ចំណូលប្រជាពលរដ្ឋកើនឡើង
- កាត់បន្ថយចំណាកស្រុក។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនសាងសងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវលំក្នុងភូមិ ស្ពាន សាលារៀន មន្ទីរពេទ្យ អណ្តូងទឹក។ល។

• អាជ្ញាធរភូមិសំពេង (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក ថោង លឿត មេភូមិសំពេង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ម៉ោង១០:៥០ នាទីព្រឹក នៅសាលាឃុំតស៊ូ ស្រុកជ័យសែន ខេត្តព្រះវិហារ។ លោកពុំជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ ព្រោះគម្រោងខាងលើនឹងជួយអភិវឌ្ឍន៍ ភូមិ ឃុំ ឲ្យមានភាពរីកចម្រើន។

ផលប៉ះពាល់

- មានការប៉ះពាល់ដល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋច្រើនគួសមដែរ។



Draft

- មានការចូលរួមដោះស្រាយពីសំណាក់គណៈកម្មការមួយចំនួនដូចជា មន្ទីរសុរិយោដី មន្ទីកសិកម្មស្រុក និងអាជ្ញាធរដែនដីដែលពាក់ព័ន្ធមួយចំនួនទៀត តែពុំទាន់រួចរាល់នៅឡើយទេ។ លោកមេភូមិកំពុងរង់ចាំការដោះស្រាយពីថ្នាក់ខេត្ត។

សំណូមពរ

- សុំឲ្យក្រុមហ៊ុនធ្វើការឈូសឆាយដីដោយទុកព្រៃខ្លះពីដីរបស់ប្រជាពលរដ្ឋ
- ផ្តល់អទិភាពខ្ពស់ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ ដើម្បីធ្វើជាកម្មករនៅក្នុងក្រុមហ៊ុន។

ជ. អាជ្ញាធរភូមិតស៊ូ (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក អ៊ុច តែន មេភូមិតស៊ូ បានធ្វើឡើងកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១១:៣៥ នាទី នៅផ្ទះលោកមេភូមិតស៊ូ។

លោកមេភូមិធ្លាប់បានដឹងពីវត្តមានគម្រោងវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (Heng Non (Cambodia) International Company Limited) ពីមុនមក។

លោកពុំជំទាស់នឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុនខាងលើនេះទេ ពីព្រោះគម្រោងវិនិយោគនេះ ធ្វើឲ្យជីវភាពប្រជាពលរដ្ឋនៅក្នុងភូមិមានភាពរីកចម្រើន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋនៅក្នុងគម្រោង ប៉ុន្តែត្រូវបានក្រុមយុវជនស្ម័គ្រចិត្ត សម្តេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិរួចហើយ

ផលប្រយោជន៍

- ប្រជាពលរដ្ឋមានការងារធ្វើ
- ប្រជាពលរដ្ឋមានជីវភាពធូរធារ
- កាត់បន្ថយភាពក្រីក្រ
- កាត់បន្ថយចំណាកស្រុក

សំណូមពរ

សូមឲ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវ ស្ពាន អណ្តូងទឹក សាលារៀន។ល។

- អាជ្ញាធរភូមិតស៊ូ (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក អ៊ុច តែន មេភូមិតស៊ូ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៦ ម៉ោង១០:៣០ នាទី នៅផ្ទះលោកមេភូមិតស៊ូ ឃុំតស៊ូ ស្រុកជ័យសែន ខេត្តព្រះវិហារ។

ផលប៉ះពាល់

- មានដីរបស់ប្រជាពលរដ្ឋប្រហែលជា៩០គ្រួសារ ដែលពាក់ព័ន្ធនឹងក្រុមហ៊ុន តែមិនទាន់ធ្វើការឈូសឆាយទៅដល់នៅឡើយ
- អាចនឹងមានការប៉ះពាល់ដល់ដីលែងសត្វរបស់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋមានការព្រួយបារម្ភចំពោះការឈូសឆាយ អាចនឹងប៉ះពាល់ដល់ដីរបស់ពួកគាត់
- មានការពិបាកក្នុងការធ្វើដំណើរ

សំណូមពរ

- សូមឲ្យក្រុមហ៊ុនកុំមានការឈូសឆាយជាលក្ខណៈស្បែកខ្លា តែក្រុមហ៊ុនអាចធ្វើការឈូសឆាយព្រៃនៅខាងជើងភូមិបាន។

៦.៤.២ ស្ថាប័ន និងមន្ទីរជំនាញពាក់ព័ន្ធ

ក. មន្ទីរបរិស្ថាន ខេត្តព្រះវិហារ

ការពិគ្រោះយោបល់ជាមួយនឹងលោក ខុយ យុនចន្ទរ័ត្ន ប្រធានមន្ទីរបរិស្ថាន ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពី ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ម៉ោង ០៨:៤៥ នាទីព្រឹក នៅមន្ទីរបរិស្ថាន ខេត្តព្រះវិហារ។

លោកប្រធានធ្លាប់បានជ្រាបពីវត្តមានរបស់ក្រុមហ៊ុនវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** តាមរយៈការចុះសិក្សាផលប៉ះពាល់បឋម។ លោកមានការគាំទ្រចំពោះគម្រោងវិនិយោគ ព្រោះក្រុមហ៊ុនវិនិយោគនេះបានជួយលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ។

ផលប្រយោជន៍

- មានចំណូលចូលរដ្ឋតាមរយៈការបង់ពន្ធ
- ប្រជាពលរដ្ឋមានការងារធ្វើ
- មានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងរួមចំណែកជួយដល់ការអភិវឌ្ឍន៍ខេត្ត
- ជួយការពាររបស់ដីរដ្ឋ
- ការបង្កើនផ្ទៃបៃតង
- មានលទ្ធភាពដើម្បីលក់កម្លាំងពលកម្មទៅឲ្យក្រុមហ៊ុន
- ជួយសម្រាលភាពលំបាករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែ និងមនុស្សជំនាន់ក្រោយ និងសតិអារម្មណ៍របស់ពួកគាត់។
- ប៉ះពាល់ធនធានធម្មជាតិ អាចបាត់បង់ដីវៃចម្រុះ សត្វព្រៃ និងជម្រកសត្វ អាចប្រែប្រួលទម្រង់បឹងធម្មជាតិ។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនអនុវត្តតាមកិច្ចសន្យាជាមួយរដ្ឋាភិបាលឲ្យបានម៉ត់ចត់
- សូមឲ្យក្រុមហ៊ុនរក្សាព្រៃស្រោងដែលមាននៅក្នុងក្រុមហ៊ុន
- សូមឲ្យក្រុមហ៊ុនរក្សាព្រៃទ្រនាប់ដងអូរ ត្រពាំង បឹងធម្មជាតិ
- សូមឲ្យក្រុមហ៊ុនទុកឲ្យប្រជាពលរដ្ឋចេញចូលប្រកបរបរក្នុងក្រុមហ៊ុនចំពោះអ្នកដែលមានដីនៅក្នុង
- សូមឲ្យក្រុមហ៊ុនជួយមើលការលំបាក និងអភិវឌ្ឍន៍ក្នុងសហគមន៍
- ពាក់ពន្ធនឹងពូជអំពៅដែលឆ្លងដែន សូមឲ្យមានការឯកភាពពីមន្ទីរជំនាញបរិស្ថាន សំខាន់សូមឲ្យមានច្បាប់នាំចូល
- សូមឲ្យក្រុមហ៊ុនកុំឲ្យប៉ះពាល់ដីរបស់ប្រជាពលរដ្ឋទោះបីរាស់ហើយ និងមិនទាន់រាស់ហើយក៏ដោយ។

ខ.មន្ទីរកសិកម្ម ខេត្តព្រះវិហារ (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក ស៊្រុន បូរិទ្ធ អនុប្រធានមន្ទីរកសិកម្ម ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៥ វេលាម៉ោង ៨:៣០នាទី នៅមន្ទីរកសិកម្ម ខេត្តព្រះវិហារ។



Draft

លោកអនុប្រធានមន្ទីរមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** តាំងពីមុនមក។

លោកឯកភាពនឹងគម្រោងអភិវឌ្ឍន៍នេះ ព្រោះគម្រោងអភិវឌ្ឍន៍ជួយអោយប្រទេសជាតិរីកចម្រើន។

ផលប្រយោជន៍

- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធដូចជា៖ សាលារៀន មន្ទីរពេទ្យ ផ្លូវ ។ល។
- ផ្តល់ចំណូលចូលរដ្ឋ
- ផ្តល់ការងារជូនប្រជាពលរដ្ឋដែលនៅក្នុង ឬក្រៅតំបន់គម្រោង
- ជួយអភិវឌ្ឍន៍ខេត្តព្រះវិហារ

ផលប៉ះពាល់

- ប៉ះពាល់ដើមដំរបោះរបស់ប្រជាពលរដ្ឋ
- ប៉ះពាល់ធនធានធម្មជាតិ (អូរ បឹង ស្ទឹង ។ល។)
- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ

សំណូមពរ

- សូមឲ្យក្រុមហ៊ុន កំណត់ព្រំរបស់ក្រុមហ៊ុនជាមួយប្រជាពលរដ្ឋឲ្យបានច្បាស់លាស់
- សូមឲ្យក្រុមហ៊ុនដោះស្រាយនៅពេលដែលក្រុមហ៊ុនឈូសឆាយប៉ះពាល់ដើមបោះដំរបស់ប្រជាពលរដ្ឋ
- សូមឲ្យក្រុមហ៊ុនផ្សព្វផ្សាយឲ្យបានទូលាយពីការធ្វើកសិកម្មតាមកិច្ចសន្យា
- សូមឲ្យក្រុមហ៊ុនរក្សាទុក តំបន់អារក្ស កន្លែងលែងសត្វ ទីជំនឿសាសនា បឹង អូរ

• **មន្ទីរកសិកម្ម ខេត្តព្រះវិហារ** (ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់លើកទី២ជាមួយនឹងលោក ស្រ៊ុន បូរិន្ទ អនុប្រធានមន្ទីរកសិកម្ម ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦ វេលាម៉ោង១៤:៤៥ នាទី នៅមន្ទីរកសិកម្ម ខេត្តព្រះវិហារ។

លោកបានជ្រាបពីវត្តមានគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង រួយ នេះពីមុនមក តាមរយៈការចុះពិនិត្យដល់ទីតាំងផ្ទាល់។ លោកមានការឯកភាព និងគម្រោងវិនិយោគខាងលើនេះ ព្រោះក្រុមហ៊ុនអាចនឹងជួយអភិវឌ្ឍន៍នៅមូលដ្ឋាន។

បច្ចុប្បន្នក្រុមហ៊ុនបានរាយការណ៍ និងធ្វើរបាយការណ៍ជាប្រចាំជូនទៅមន្ទីរកសិកម្មត្រួតពិនិត្យ។ ចំពោះទីតាំងគម្រោង គឺមិនរើសប្រភេទដំណាំទេ និងមានសក្តានុពលខ្ពស់សម្រាប់ដំណាំអំពៅ លើសពីនេះទៅទៀត មានប្រជាជនមួយចំនួនបានសហការ និងធ្វើកិច្ចសន្យាក្នុងការដាំដំណាំអំពៅ ដោយមានមន្ទីរកសិកម្ម និងមន្ទីរពាក់ព័ន្ធជាសាក្សី ហើយក្រុមហ៊ុនបានអនុវត្តទៅតាមផែនការមេដែលចេញដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

ផលប្រយោជន៍

- កាត់បន្ថយការចំណាកស្រុក
- ស្រូបយកកំលាំងពលកម្មក្នុងស្រុក
- ជ្រើសរើសកម្មករខ្មែរទោះបណ្តុះបណ្តាលផ្ទេរបច្ចេកទេសពីប្រទេសចិន
- បង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន ដូចជា វត្តអារាម សាលារៀន ផ្លូវលំ អគ្គិសនី។ល។

ផលប៉ះពាល់

- អាចនឹងបង្ករឲ្យខូចគុណភាពដី និងគុណភាពដី ប្រសិនបើក្រុមហ៊ុនមិនបានប្រើប្រាស់តាមបច្ចេកទេស

សំណូមពរ

- សូមក្រុមហ៊ុនសហការល្អវាំងអង្គាធរ និងមន្ទីរពាក់ព័ន្ធ
- សូមក្រុមហ៊ុនមានការអនុគ្រោះដល់ដីប្រជាជនឲ្យបានច្រើន
- មន្ទីរកសិកម្មមានផែនការ និងបានផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ដំណាំអំពៅដោយធ្វើការប្រៀបធៀបដំណាំអំពៅ និងស្រូវ រយៈពេល១ឆ្នាំ ១ហិកតា ជាលទ្ធផលគឺដំណាំអំពៅមានប្រសិទ្ធភាពខ្ពស់ជាងដំណាំស្រូវ

គ. មន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ

ការពិគ្រោះយោបល់ជាមួយនឹងលោក គង់ មករា ប្រធានមន្ទីរ រ៉ែ និងថាមពល ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៤ វេលាម៉ោង ០៨:៣៥ នាទី នៅមន្ទីរ រ៉ែ និងថាមពល ខេត្តព្រះវិហារ។

លោកប្រធានមន្ទីរមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបអំពីវត្តមានគម្រោងអភិវឌ្ឍន៍ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត (Heng Non (Cambodia) International Company Limited) ពីមុនមក តាមរយៈការចុះសិក្សាទីតាំងផ្ទាល់។ លោកប្រធានពុំជំទាស់ចំពោះគម្រោងអភិវឌ្ឍន៍ នៅក្នុងតំបន់នេះទេ ព្រោះការអភិវឌ្ឍន៍ធ្វើឲ្យសេដ្ឋកិច្ចមាន ការរីកចម្រើន និងមានហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ។

ផលប្រយោជន៍

- មានកំណើនសេដ្ឋកិច្ចចូលរដ្ឋតាមរយៈការបង់ពន្ធ
- ប្រជាពលរដ្ឋមានការងារធ្វើ និងមានជីវភាពប្រសើរជាងមុន
- កាត់បន្ថយការធ្វើចំណាកស្រុក
- មានហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានល្អប្រសើរ ដូចជា ផ្លូវ ទឹកស្អាត។ល។

ផលប៉ះពាល់

- ប៉ះពាល់លើទៅលើក្រុមហ៊ុនរុករករ៉ែរបស់ក្រុមហ៊ុន Mekong Mining ប៉ុន្តែក្រុមហ៊ុននេះពុំទាន់ធ្វើដំណើរការរបស់ខ្លួននៅឡើយទេ។
- ប៉ះពាល់ទៅលើដីស្រែចម្ការរបស់ប្រជាពលរដ្ឋ។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនជ្រើសរើសពលកម្មក្នុងមូលដ្ឋានទៅបម្រើការងារក្នុងទីតាំងគម្រោង និងជួយបង្រៀនបច្ចេកទេសដល់ប្រជាពលរដ្ឋ។
- សូមឲ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យាដែលក្រុមហ៊ុនបានធ្វើជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- សូមឲ្យក្រុមហ៊ុនគោរពប្រពៃណី វប្បធម៌របស់ជនជាតិដើមភាគតិច។
- ចំពោះការប៉ះពាល់ទៅលើក្រុមហ៊ុនរុករករ៉ែ សុំឲ្យក្រុមហ៊ុនអនុវត្តន៍តាមគោលការណ៍សម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

Draft

ឃ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ (ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក សរ សាវេត អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៤ វេលាម៉ោង០៩:៤៥ នាទីព្រឹក នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ។

លោកបានជ្រាបអំពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** នេះពីមុនមក។ លោកពុំជំទាស់លើគម្រោងដីសម្បទានសេដ្ឋកិច្ចខាងលើនេះទេ ព្រោះគម្រោងនេះជួយអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការ រីកចម្រើន ។

ផលប្រយោជន៍

- លើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារ
- ប្រជាពលរដ្ឋក្នុងមូលដ្ឋានមានការងារធ្វើ
- ប្រជាពលរដ្ឋទទួលបានគ្រាប់ពូជពីក្រុមហ៊ុន។

ផលប៉ះពាល់

- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋក្នុងឃុំតស៊ូ និងឃុំស្អាង ប៉ុន្តែក្រុមយុវជនស្ម័គ្រចិត្ត សម្តេចតេជោ បានចុះវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិ ជូនប្រជាពលរដ្ឋរួចរាល់ហើយ ។

សំណូមពរ

- សូមឲ្យក្រុមហ៊ុន សហការណ៍ល្អជាមួយមន្ទីរដែនដីខេត្តព្រះវិហារ ក្នុងការសាងសង់សំណង់ក្នុងទីតាំងគម្រោង
- សូមឲ្យខាងក្រុមហ៊ុនមកកាត់ឈ្មោះ ប្លង់ដី ដែលបានដោះដូរ (ទិញ) ពីប្រជាពលរដ្ឋរួចជៀសវាងមានទំនាស់នៅថ្ងៃក្រោយ។

• មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ(ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក គង់ សោភ័ណ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៦ វេលាម៉ោង១៤:៤០ នាទី នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះវិហារ។

លោកបានជ្រាបពីវត្តមានគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង នេះពីមុនមក។ លោកបានឯកភាពនឹងគម្រោងវិនិយោគនេះ ព្រោះគម្រោងនេះជួយអភិវឌ្ឍន៍ប្រទេសជាតិតាមរយៈការបង់ពន្ធ និងជួយកាត់បន្ថយភាពក្រីក្រតាមមូលដ្ឋាន ក៏ដូចជាប្រទេសជាតិទាំងមូល។

ផលប៉ះពាល់

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី បានចុះបញ្ជីដីធ្លីក្នុងភូមិសំរោង ចំនួន ១៤ក្បាលដី ស្មើនឹង៦៧ហិកតា។ ស្រុកត្បែងមានជ័យចំនួន ៤០៤ ក្បាលដី បានវាស់វែងរួច និងកាត់ហើយចំនួន ៥១ គ្រួសារ។

ផលប្រយោជន៍

- ផ្តល់ការងារជូនដល់ប្រជាពលរដ្ឋមូលដ្ឋាន

- ប្រជាពលរដ្ឋមានប្រាក់ចំណូលកើនឡើង
- មានហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ដូចជា: សាលារៀន ផ្លូវ មណ្ឌលសុខភាព វត្តអារាម....
- កាត់បន្ថយការចំណាកស្រុក

**សំណូមពរ**

- សូមឲ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យារវាងក្រុមហ៊ុន និងអ្នកពាក់ព័ន្ធផ្សេងៗ
- សូមឲ្យក្រុមហ៊ុនជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ដូចជា: សាលារៀន ផ្លូវ អណ្តូងទឹក វត្តអារាម បន្ទាប់ពីក្រុមហ៊ុនបានដំណើការ

**ង. មន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រះវិហារ**

ការពិគ្រោះយោបល់ជាមួយនឹងលោក ចាប កុយ ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៩:១០ នាទីនៅមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រះវិហារ។

លោកប្រធានមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបអំពីវត្តមានគម្រោងវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** ពីមុនមក។ លោកពុំជំទាស់ទៅនឹងគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុននេះទេ ព្រោះគម្រោងនេះជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល។

**ផលប្រយោជន៍**

- ស្រូបយកកម្លាំងពលកម្មក្នុងស្រុក
- កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋក្នុង និងក្បែរទីតាំងគម្រោងមានជីវភាពធូរជាតាមរយៈប្រាក់ចំណូល
- មានចំណូលចូលរដ្ឋតាមរយៈការបង់ពន្ធ
- នាំស្ករអំពៅចេញទៅក្រៅប្រទេស

**សំណូមពរ**

- សូមឲ្យក្រុមហ៊ុនរក្សាព្រៃទ្រនាប់ដងអូរ ៧០កាគរយ ក្នុងគម្រោង
- សូមឲ្យក្រុមហ៊ុនរក្សា អូរ បឹង ចាស់ៗក្នុងគម្រោង។

**ច. មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ(ការជួបពិគ្រោះយោបល់លើកទី១)**

ការពិគ្រោះយោបល់ជាមួយនឹងលោក នៅ សុគុណ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារត្រូវបានធ្វើឡើងកាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៣:១០ នាទីរសៀល នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ។

លោកប្រធានធ្លាប់បានជ្រាបអំពីវត្តមានគម្រោងវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** ពីមុនមក។ លោកពុំជំទាស់ចំពោះគម្រោងដីសម្បទានសេដ្ឋកិច្ចនេះទេ ហើយម្យ៉ាងទៀតវាគ្មានអ្វីពាក់ព័ន្ធចំពោះការដាំដំណាំនេះទេ។

**ផលប្រយោជន៍**

- កាត់បន្ថយភាពក្រីក្រ
- ប្រាក់ចំណូលគ្រួសារកើនឡើង

- កាត់បន្ថយចំណាកស្រុក
- សេដ្ឋកិច្ចជាតិកើនឡើង តាមរយៈការយកពន្ធ
- ផ្តល់ការងារជូនប្រជាពលរដ្ឋនៅក្នុងតំបន់ធ្វើ

សំណូមពរ

- ពេលដែលឈូសឆាយបើសិនបានជួបប្រទះនូវគ្រឿងប្រាសាទ ទួល ស្រះ ឡស្លដែក...
- សូមឲ្យខាងក្រុមហ៊ុនវិនិយោគ រាយការណ៍មកមន្ទីរជាបន្ទាន់ ដើម្បីមន្ទីរចុះទៅសិក្សាកំណត់ព្រំដីនៅ ទីនោះ ហើយកុំឲ្យវាមានបាតុភាពអ្វីមួយកើតមានឡើង ហើយទើបរាយការណ៍ប្រាប់មន្ទីរ។

• មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ(ការជួបពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក នៅ សុគុណ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ៩:១៥ នាទីព្រឹក នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ។ លោកបានមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបអំពីវត្តមានគម្រោងវិនិយោគ របស់ក្រុមហ៊ុន ហេង ណុង ពីមុនមក។ លោកពុំជំទាស់ចំពោះគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង នោះទេ ព្រោះគម្រោងនេះអាចជួយធ្វើឲ្យប្រជាពលរដ្ឋ មានប្រាក់ចំណូលខ្ពស់ និងរួមចំណែកអភិវឌ្ឍន៍។ បច្ចុប្បន្នមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ បានបោះបង្គោលរួចរាល់ហើយ។

ផលប្រយោជន៍

- កាត់បន្ថយភាពក្រីក្រ
- មានចំណូលចូលរដ្ឋតាមរយៈការបង់ពន្ធ
- ប្រជាពលរដ្ឋមានការងារធ្វើ
- ការបន្ថយការចំណាកស្រុក

សំណូមពរ

- ករណីឈូសឆាយដីប៉ះខឿន ឬទីទួលប្រសាទ ក្រុមហ៊ុនត្រូវសហការជាបន្ទាន់ជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចុះកំណត់ទីតាំង និងធ្វើការសិក្សា។
- សូមក្រុមហ៊ុនជួយណែនាំដល់ក្រុមហ៊ុនម៉ៅការ ពីការឈូសឆាយដីព្រៃឲ្យបានច្បាស់លាស់។

ឆ. មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារ

ការពិគ្រោះយោបល់ជាមួយនឹងលោក សំ លាងទ្រី ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ៨:៣៥ នាទីព្រឹក នៅមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះវិហារ។

លោកបានជ្រាបអំពីវត្តមានគម្រោងដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគ ដាំដំណាំអាកាស្យា និងអំពៅរបស់ក្រុមហ៊ុន ហេង ណុង នេះពីមុនមកតាមរយៈការរាយការណ៍ និងផ្តល់ពត៌មានជូន មន្ទីរសាធារណៈការ និងដឹកជញ្ជូន ប៉ុន្តែមិនជាក់លាក់ទេ។ លោកមានការឯកភាព និងគម្រោងវិនិយោគខាងលើនេះ ព្រោះក្រុមហ៊ុនអាចនឹងជួយអភិវឌ្ឍន៍ប្រទេសជាតិ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ផលប៉ះពាល់

- អ្នកបើកបរឬអ្នកដឹកអំពៅក្មេងៗពេក និងបើកបរលឿនហួសកំណត់
- ការដឹកអំពៅរបស់ក្រុមហ៊ុន គឺធ្លាក់ប៉ោតប៉ោយពេញផ្លូវ ប៉ុន្តែមិនបានដឹកលើសទំងន់ទេ អ្វីដែលជាបញ្ហា គឺដឹកសំពីងសំពោង

- ក្រុមហ៊ុនធ្លាប់ដឹកសម្ភារៈ គ្រឿងចក្រ ខ្សាច់ ថ្ម លើសទំងន់
- ក្រុមហ៊ុនធ្លាប់បានបុកស្លាកសញ្ញាធំមួយនៅស្រុកឆែប។

ផលប្រយោជន៍

- កំណើនសេដ្ឋកិច្ចជាតិតាមរយៈការបង់ពន្ធ
- ប្រជាពលរដ្ឋមានការងារធ្វើ
- ប្រាក់ចំណូលប្រជាពលរដ្ឋកើនឡើង
- កាត់បន្ថយការចំណាកស្រុក

សំណូមពរ

- សូមឲ្យក្រុមហ៊ុនអនុវត្តដំណើការរបស់ខ្លួនតាមផែនការមេ និងកិច្ចសន្យាដែលបានធ្វើជាមួយរដ្ឋាភិបាល

➢ **ទិសដៅរបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូន**

- មានគម្រោងសាងសង់ស្ពាននៅឃុំកំពុងស្រឡៅ ស្រុកឆែប ខេត្តព្រះវិហារ ដោយឆ្លងកាត់ទន្លេល្ពៅតភ្ជាប់ទៅប្រទេសឡាវ និងបើកច្រកអន្តរជាតិធំមួយ។

**ជ. មន្ទីរអភិវឌ្ឍជនបទ ខេត្តព្រះវិហារ**

ការពិគ្រោះយោបល់ជាមួយនឹងលោក សេង សារី ប្រធានមន្ទីរអភិវឌ្ឍជនបទ ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១៤:៣៥ នាទី នៅមន្ទីរអភិវឌ្ឍជនបទ ខេត្តព្រះវិហារ។

លោកប្រធានមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបពីវត្តមានរបស់ក្រុមហ៊ុនវិនិយោគខាងលើនេះពីមុនមក តាមរយៈការចូលរួមដោះស្រាយវិវាទដីធ្លី ជាមួយមន្ទីរដែនដី។ ក្រុមហ៊ុនមិនទាន់បានទំនាក់ទំនង និងសហការជាមួយមន្ទីរនៅឡើយទេ លើផ្នែកបច្ចេកទេស ផ្លូវលំ និងទឹកស្អាត។

លោកប្រធានឯកភាពនឹងគម្រោងវិនិយោគខាងលើនេះ ព្រោះគម្រោងបានជួយអភិវឌ្ឍដល់សហគមន៍មូលដ្ឋាន ក៏ដូចជាចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

ផលប្រយោជន៍

- ប្រជាពលរដ្ឋមានការងារធ្វើ
- ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកើនឡើង
- កាត់បន្ថយចំណាកស្រុក
- បង្កើនប្រាក់ចំណូលចូលរដ្ឋ តាមរយៈការបង់ពន្ធ
- មានឱកាសរៀនបច្ចេកទេសពីប្រទេសចិន

ផលប៉ះពាល់

- ក្រុមហ៊ុនមិនទាន់បង្កផលប៉ះពាល់ជុំវិញទីតាំងគម្រោងនៅឡើយ ពិសេស ផ្លូវលំ និងទឹកស្អាត

សំណូមពរ

- សូមឲ្យក្រុមហ៊ុនសហការល្អជាមួយមន្ទីរ និងអាជ្ញាធរពាក់ព័ន្ធ
- សូមឲ្យក្រុមហ៊ុនជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា៖ សាលារៀន ផ្លូវលំ វត្តអារាម អណ្តូងទឹក ពិសេសទឹកស្អាត
- មុនពេលឈូសឆាយដីព្រៃ សូមឲ្យក្រុមហ៊ុនរាយការណ៍ និងសហការល្អដល់អាជ្ញាធរ និងមន្ទីរពាក់ព័ន្ធ
- សូមឲ្យក្រុមហ៊ុនមានផែនការអនុវត្តច្បាស់លាស់ ដើម្បីឲ្យមន្ទីរពាក់ព័ន្ធចូលរួមផ្តល់យោបល់ និងវាយតម្លៃលើបទដ្ឋានគតិយុទ្ធ។

ឈ. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះវិហារ

ការពិគ្រោះយោបល់ជាមួយនឹងលោក ហេង កុយ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៦ វេលាម៉ោង ១៤:៣៥ នាទី នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រះវិហារ។

លោកប្រធានបានជ្រាបពីវត្តមានរបស់ក្រុមហ៊ុនខាងលើនេះ ពីមុនមក តាមរយៈការចុះអធិការកិច្ចទីតាំងផ្ទាល់ និងការរៀបចំប្រជុំគណអភិបាលខេត្ត។ ក្រុមហ៊ុនខាងលើនេះបានអនុវត្តលក្ខខណ្ឌការងារបានល្អជាងគេ ព្រោះក្រុមហ៊ុនបានគោរពនូវច្បាប់ការងារ រួមទាំងរបបអាហារសម្រាប់កម្មករចំនួន ០៣ពេល។

ចាត់តាំងពីឆ្នាំ ២០១៨ រហូតមកដល់បច្ចុប្បន្នក្រុមហ៊ុនមិនទាន់មានវិវាទ ឬពាក្យបណ្តឹងនៅឡើយទេ (បណ្តឹងជាមួយបុគ្គលិក-កម្មករ និងថៅកែ)។ បច្ចុប្បន្នក្រុមហ៊ុនបានរាយការណ៍ និងបញ្ជូនរាល់ព័ត៌មានអំពីការចេញ ចូលរបស់បុគ្គលិក មកមន្ទីរការងារ។

លោកប្រធានឯកភាពនឹងគម្រោងវិនិយោគខាងលើនេះ ព្រោះគម្រោងខាងលើនេះ ជួយលើកមុខមាត់ប្រទេសកម្ពុជា ក៏ដូចជាធ្វើឲ្យប្រទេសដទៃទៀតស្គាល់។

ផលប្រយោជន៍

- ផ្តល់ការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ
- កាត់បន្ថយការចំណាកស្រុក
- ប្រទេសជាតិមានចំណូលច្រើនតាមរយៈការបង់ពន្ធ

សំណូមពរ

- សូមឲ្យក្រុមហ៊ុនផ្តល់ជាអាហារូបករណ៍ ដល់មន្ត្រីរបស់មន្ទីរការងារ ដើម្បីបានបន្តការសិក្សានៅប្រទេសចិន អំពីច្បាប់ ឬផ្នែកកសិកម្មជាដើម
- សូមឲ្យក្រុមហ៊ុនបន្តក្នុងការបញ្ជូនកម្មករ ទៅរៀនពីបច្ចេកទេសថ្មីៗពីបរទេស។

ការចុះអធិការកិច្ចលើវិស័យការងារផ្ទាល់នៅសហគ្រាស/គ្រឹះស្ថាន និងការរៀបចំប្រជុំគណៈអភិបាលខេត្ត ក៏ដូចជាការប្រជុំនៅគ្រឹះស្ថានក្រុមហ៊ុនផ្ទាល់។

លទ្ធផល

១. ក្រុមហ៊ុនបានចុះបញ្ជីការ លើវិស័យការងារ

២. ក្រុមហ៊ុនបានប្រកាសចលនាបុគ្គលិក

៣. អនុវត្តច្បាប់ លិខិតបទដ្ឋានស្តីពីការងារជាជំហានៗ

ញ. ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ(ការជួបពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក នង ខេមរិន្ទ នាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ វេលាម៉ោង ០៨:០០ នាទី នៅខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ។

លោកនាយរងខណ្ឌមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** តាំងពីមុនមក តាមរយៈលិខិតបទដ្ឋានដែលរាជរដ្ឋាភិបាលបានអនុញ្ញាត លិខិត២២៩ សជណ/ ២៨/០២/២០១១ សម្រាប់ក្រុមហ៊ុនទាំង៥។ ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារគាំទ្រ ប៉ុន្តែក្រុមហ៊ុនត្រូវតែ អនុវត្តតាមអ្វីដែលច្បាប់ចែង។

Draft

នៅក្នុងតំបន់ស្នើសុំមានព្រៃ៤ប្រភេទ ១/២ព្រៃស្រោង ស្មើនឹង ៥៨១ហិកតា ព្រៃល្បោះ ស្មើនឹង ១១.៥៦៧ ហិកតា ព្រៃផ្សេងៗ ស្មើនឹង ០៨ហិកតា ដីគ្មានគម្របព្រៃ ស្មើនឹង ១៦៤ហិកតា។ ចំពោះឈើដែលមានតម្លៃពាណិជ្ជកម្មអាចមាននៅសល់ខ្លះក្រៅពីវាលចម្ការប្រជាពលរដ្ឋ ពិសេសតាមតំបន់ទ្រនាប់ដងអូរ និង១/២ស្រោង។

ផលប្រយោជន៍

- បម្រើឲ្យសេដ្ឋកិច្ចជាតិមួយផ្នែក
- ផ្តល់ការងារឲ្យប្រជាពលរដ្ឋដើម្បីកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ផលប៉ះពាល់

- បាត់បង់តុល្យភាពជីវៈចម្រុះ
- ព្រៃតំបន់នោះរងការបំផ្លាញចំពោះឈើពាណិជ្ជកម្មប្រើប្រាស់
- បាត់បង់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលធ្លាប់អាស្រ័យផល អំពីព្រៃនេះ
- ប៉ះពាល់ជម្រកសត្វព្រៃ និងសំបុកពងកូន នៅតំបន់ឈូសឆាយ
- អាចប៉ះពាល់ដល់ផ្លូវទឹកធម្មជាតិ និងធ្វើឲ្យរីង រាក់ ចំពោះស្ទឹង បឹង ធម្មជាតិដែលទទួលជាទឹកពីតំបន់នោះ...។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនរក្សាទុកតំបន់ព្រៃដែលមានកំណត់ក្នុងកិច្ចសន្យាឲ្យបាន
- ក្រុមហ៊ុនត្រូវធ្វើការឈូសឆាយឆ្លាស់គ្នាដើម្បីឲ្យសត្វមានឱកាសផ្លាស់ប្តូរទីកន្លែងរស់នៅ
- ក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះក្រុមហ៊ុនឈូសឆាយ ដែលតែងតែឈូសឆាយដល់មាត់អូរ បឹង...។
- សូមឲ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យាដែលបានធ្វើជាមួយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។
- សូមឲ្យក្រុមហ៊ុនសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានជាប្រចាំ ពេលអនុវត្តការឈូសឆាយតាមលិខិតអនុញ្ញាតរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- សូមឲ្យក្រុមហ៊ុនដាំដើមឈើឡើងវិញ ចំពោះការឈូសឆាយជ្រុលជ្រួសកន្លងមក ករណីមានការឈូសតាមមាត់ស្ទឹង បឹងធម្មជាតិ។
- រាល់ការប្រមូលផល (កាកសំណល់) ឲ្យអស់លទ្ធភាពមុនធ្វើការដុតកម្ទេច។
- មុនដុតកម្ទេចកាកសំណល់ចុងក្រោយ ត្រូវធ្វើលិខិតមករដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដើម្បីធ្វើ ការវាយតម្លៃជាមុនដាច់ខាត។
- មិនអនុញ្ញាតឲ្យក្រុមហ៊ុនឈូសឆាយព្រៃដោយគ្មានលិខិតអនុញ្ញាតដាច់ខាត។

- ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ (ការជួបពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក នង ខេមរិន្ទ នាយរងខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ០៨:៣០ នាទី នៅខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ។ លោកនាយរងខណ្ឌមានប្រសាសន៍ថា លោកធ្លាប់បានជ្រាបពីគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ហេង ណុង តាំងពីមុនមកហើយ ដោយសារគម្រោងនេះបានអនុវត្តន៍យូរមកហើយ។

Draft

ផលប៉ះពាល់

- មានបញ្ហាដីធ្លីនៅតែកើតឡើង ដោយសារតែប្រជាពលរដ្ឋមិនព្រមទទួលយកដំណោះស្រាយ ជាហេតុធ្វើឲ្យមានការពិបាកក្នុងការដោះស្រាយ តែគណកម្មាការដោះស្រាយដីធ្លី និងក្រុមហ៊ុននៅតែបន្តដោះស្រាយបន្តទៀត
- ការឈូសឆាយដីរបស់ក្រុមហ៊ុនក៏ជាហេតុមួយដែលបណ្តាលឲ្យមានផលប៉ះពាល់ដែរ ដោយសារតែខាងក្រុមហ៊ុនបានជួលភាគគីម្ខាងទី២ ហើយភាគគីទី២បានធ្វើការជួលទៅភាគគីបន្តទៀត ឲ្យធ្វើការឈូសឆាយនាំឲ្យមានលក្ខណៈខុសបច្ចេកទេស (ឈូសចូលដល់ព្រៃរក្សាទុក)
- ក្រុមហ៊ុនមិនបានគោរពលើការណែនាំក្នុងការប្រមូលសំណល់រឹង ដោយក្រុមហ៊ុនបានដុតសំណល់ចោលទាំងអស់។
- ថ្មីៗនេះខាងក្រុមហ៊ុនបានធ្វើការឈូសឆាយដីព្រៃ ប៉ុន្តែមិនបានដកហូតឈើហ៊ុបមកបង់ពន្ធទេ ដោយក្រុមហ៊ុនបានធ្វើការដុតឈើនោះទាំងអស់។ អ្នកជំនាញរបស់រដ្ឋបាលព្រៃឈើ បានចុះធ្វើការណែនាំពីបញ្ហានេះដបន្តបន្ទាប់។
- បញ្ហាដែលបង្កឲ្យដីវិនិយោគរបស់ក្រុមហ៊ុនកាន់តែតូចទៅៗ ដោយសារតែមានការរំលោភបំពានតាមគ្រប់រូបភាព។

សំណូមពរ

- សូមឲ្យខាងក្រុមហ៊ុនជួយថែរក្សាការពារព្រៃឈើរក្សាទុកដែលមានដូចជា ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃការពារតាមទ្រនាប់ដងអូរ។
- សូមឲ្យក្រុមហ៊ុនធ្វើការប្រមូលសំណល់ដែលបានឈូសឆាយហើយ ដើម្បីបង់ពន្ធជូនរដ្ឋ ដោយមានការសហការជាមួយខណ្ឌរដ្ឋបាលព្រៃឈើឲ្យអស់ពីលទ្ធភាព។ ក្រុមហ៊ុនត្រូវអនុវត្តទៅតាមផែនការមេ ដែលមានចែងនៅក្នុងកិច្ចសន្យាជាមួយរដ្ឋាភិបាល។

ជ. ខណ្ឌរដ្ឋបាលជលផលព្រះវិហារ(ការពិគ្រោះយោបល់លើកទី១)

ការពិគ្រោះយោបល់ជាមួយនឹងលោក ប៉ែន វាសនា នាយខណ្ឌរដ្ឋបាលជលផលព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ០៤:៣០ នាទីរសៀល នៅខណ្ឌរដ្ឋបាលជលផលព្រះវិហារ។

លោកពុំធ្លាប់បានជ្រាបអំពីវត្តមានដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដំណាំ អាកាស្យា និងអំពៅរបស់ក្រុមហ៊ុន ហេង ណុង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត **(Heng Non (Cambodia) International Company Limited)** នេះពីមុនមកទេ។ លោកពុំជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ ព្រោះអាចធ្វើឲ្យសេដ្ឋកិច្ចជាតិកើនឡើង និងអភិវឌ្ឍន៍មូលដ្ឋានឲ្យមានការរីកចម្រើន។

ផលប្រយោជន៍

- កាត់បន្ថយការចំណាកស្រុក
- កាត់បន្ថយភាពក្រីក្រ
- ប្រជាពលរដ្ឋមានការងារធ្វើ
- ប្រាក់ចំណូលប្រជាពលរដ្ឋកើនឡើង។

ផលប៉ះពាល់

- ប៉ះពាល់ទៅលើការហូរច្រោះដី
- ប៉ះពាល់ទឹកដោយសារការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម



Draft

- បាត់បង់ជម្រកត្រី និងប្រភពចំណីអាហាររស់វា
- បាត់បង់នូវគម្របដីខាងលើដែលធ្វើឲ្យប្រែប្រួលនូវលក្ខណៈដីវសាស្ត្រអូរ។

សំណូមពរ

- សូមឲ្យក្រុមហ៊ុនរាយការណ៍មកខណ្ឌរដ្ឋបាលជលផលចំពោះការដឹកប្រឡាយក្នុងតំបន់គម្រោង។

• ខណ្ឌរដ្ឋបាលជលផលព្រះវិហារ(ការពិគ្រោះយោបល់លើកទី២)

ការពិគ្រោះយោបល់ជាមួយនឹងលោក អេង គឹមឡេង នាយរងខណ្ឌរដ្ឋបាលជលផល ខេត្តព្រះវិហារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១៧:៤០នាទី នៅខណ្ឌរដ្ឋបាលជលផល ខេត្តព្រះវិហារ។

លោកបានជ្រាបពីវត្តមានគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច សម្រាប់ការវិនិយោគដាំដំណាំអាកាស្យា និងអំពៅ របស់ក្រុមហ៊ុន ហេង ណុង នេះពីមុនមក តាមរយៈការចុះអង្កេតរបស់ខណ្ឌរដ្ឋបាលជលផល។ លោកបានមានប្រសាសន៍បានថា នៅក្នុងទីតាំងគម្រោងមានប្រភេទត្រីដូចជា ត្រីឆ្លាំង ត្រីខ្ចឹង ត្រីឆ្តូញ ត្រីអណ្តែង ត្រីរ៉ស ត្រីក្រពាត់ ត្រីក្អែក ត្រីដំរី និងត្រីកញ្ចុះថ្ម...ហើយខណ្ឌរដ្ឋបាលជលផលទើបតែចុះទៅសិក្សាអំពីហេតុប៉ះពាល់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ឃើញថាមានផលប៉ះពាល់តិចតួចប៉ុណ្ណោះពីសំណាក់បុគ្គលិក-កម្មកររបស់ គម្រោង។

បច្ចុប្បន្នខណ្ឌរដ្ឋបាលជលផលបានបង្កើតស្រះជម្រកត្រីសហគមន៍ក្នុងខេត្តព្រះវិហារ ប៉ុន្តែមិនទាន់បង្កើតនៅជិត ឬក្បែរតំបន់គម្រោងនៅឡើយទេ។

ផលប្រយោជន៍

- ផ្តល់ការងារជូនដល់ប្រជាពលរដ្ឋមូលដ្ឋាន
- ប្រជាពលរដ្ឋមានប្រាក់ចំណូលកើនឡើង
- កាត់បន្ថយការចំណាកស្រុក

សំណូមពរ

- សូមឲ្យក្រុមហ៊ុនរក្សាទុកតំបន់ដែលមានទឹកជ្រៅ
- សូមឲ្យក្រុមហ៊ុនរក្សាទុកអូរធំៗ បឹងធម្មជាតិ កន្លែងអភិរក្ស ស្រះទឹកសហគមន៍
- សូមឲ្យក្រុមហ៊ុន ជួយលែងកូនត្រីនៅក្នុងទីតាំងគម្រោង

តារាង ៦.១ តារាងសង្ខេបពីមតិយោបល់របស់អាជ្ញាធរពាក់ព័ន្ធ

| អ្នកពាក់ព័ន្ធ | មតិយោបល់ | សំណូមពរ |
|---|---|---|
| ក. អាជ្ញាធរពាក់ព័ន្ធ | | |
| ឯកឧត្តម ស៊ូ សិរី អភិបាលរងខេត្តព្រះវិហារ | ឯកឧត្តមមានប្រសាសន៍ថា ឯកឧត្តមយល់ស្របនឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុន និងឯកភាពនូវការលើកឡើងរបស់លោកអភិបាលស្រុកជ័យសែន ពីការរក្សាទុកដី ១០% សម្រាប់ទុកជូនគ្រួសារក្រីក្រអ្នកទើបរៀបការរួច។ | |
| លោក ថោង សាគឿន អភិបាលនៃគណៈអភិបាលស្រុកជ័យសែន | - លោកអភិបាលស្រុកមានប្រសាសន៍ថា លោកធ្លាប់បានជ្រាប និងឯកភាពនឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុនខាងលើនេះ។ | - សូមឲ្យក្រុមហ៊ុន ជួយសាងសង់ស្ពាន និងផ្លូវតភ្ជាប់ពីផ្លូវមេរបស់ក្រុមហ៊ុន ទៅកាន់ទីរួមស្រុកជ័យសែន។ |



Draft

| | | |
|---|---|---|
| | | - សូមឲ្យក្រុមហ៊ុន ទទួលទិញដំណាំអំពៅរបស់ប្រជាពលរដ្ឋ ដែលនៅក្រៅតំបន់គម្រោង។<br>- សូមឲ្យអភិបាលខេត្ត បន្តបង្កើតក្រុមយុទ្ធនាការណ៍វាស់វែងដីធ្លី ដែលនៅសល់ក្នុងតំបន់គម្រោង។ |
| លោក មាស សិត យុំស្អាង (ការពិគ្រោះយោបល់លើកទី១) | - លោកធ្លាប់បានជ្រាប និងយល់ស្របនឹងគម្រោងវិនិយោគនេះ។<br>- ប៉ះពាល់ដីស្រែចម្ការនៅក្នុង ភូមិស្អាង និងភូមិគោក ប្រមាណ ១៥០គ្រួសារ ប៉ុន្តែ ភូមិស្អាងក្រុមយុវជនស្ម័គ្រចិត្ត សម្តេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋអស់ហើយ | - សូមឲ្យក្រុមហ៊ុនកាត់ដីដែលពាក់ពន្ធរបស់ប្រជាពលរដ្ឋចេញពីទីតាំងដីវិនិយោគ<br>- សូមឲ្យក្រុមហ៊ុនជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ស្ពាន អណ្តូងទឹក ស្រះ<br>- សូមឲ្យបន្តវាស់វែងដីនៅក្នុងភូមិគោក<br>- សូមឲ្យក្រុមហ៊ុនសាងសង់ សាលាឃុំថ្មី និងបណ្តាញអគ្គីសនីនៅសាលាឃុំ។ |
| លោក មាស សិត យុំស្អាង (ការពិគ្រោះយោបល់លើកទី២) | - ប៉ះភូមិចំនួន០២ គឺភូមិស្អាង និងភូមិគោក។ មកដល់ បច្ចុប្បន្នក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយស្ទើរតែរួចរាល់អស់ហើយ។ លោកមេឃុំ មិនទាន់ក្តាប់បានអំពីចំនួនគ្រួសារ និងទំហំផ្ទៃដីនៅឡើយទេ។ | |
| លោកស្រី កៅ គឹមធី មេភូមិស្អាង (ការពិគ្រោះយោបល់លើកទី១) | - លោកស្រីធ្លាប់បានជ្រាប និងឯកភាពនឹងគម្រោងអភិវឌ្ឍន៍ខាងលើនេះ។<br>- ប៉ះពាល់ដីស្រែចម្ការ ប៉ុន្តែក្រុមយុវជនស្ម័គ្រសម្តេចតេជោបានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋរួចរាល់ហើយ | - សូមឲ្យក្រុមហ៊ុន អភិវឌ្ឍន៍ហេដ្ឋារចនា-សម្ព័ន្ធក្នុងមូលដ្ឋានដូចជា អណ្តូងទឹក សាលារៀន ផ្លូវលំ ស្ពារលូ។<br>- សូមឲ្យក្រុមហ៊ុន ជួយចាក់ដីនៅសាលាធទានក្នុងភូមិកុំឲ្យលិចទឹក។ |
| លោកស្រី កៅ គឹមធី មេភូមិស្អាង (ការពិគ្រោះយោបល់លើកទី២) | - ដីប៉ះពាល់ជាមួយក្រុមហ៊ុន គឺមានតិចតួចប៉ុណ្ណោះ។ អ្នកស្រីមេភូមិមិនអាចក្តាប់ព័ត៌មានពីចំនួនគ្រួសារ និងទំហំដីរបស់ប្រជាពលរដ្ឋ ដែលប៉ះពាល់ជាមួយក្រុមហ៊ុនទេ<br>- បច្ចុប្បន្នក្រុមហ៊ុនមិនទាន់បានអភិវឌ្ឍន៍ដល់ភូមិឃុំដូចជា ផ្លូវ សាលា រៀន អណ្តូងទឹកនៅឡើយ។ | - សុំឲ្យក្រុមហ៊ុនជួយសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័នដូចជាផ្លូវថ្នល់ សាលារៀន អណ្តូងទឹក និងវត្តអារាម។ |
| លោក មាន ម៉ៅ មេភូមិគោក (ការពិគ្រោះយោបល់លើកទី១) | - លោកធ្លាប់បានជ្រាប និងមិនជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ ភូមិចំនួន ១១០គ្រួសារ | - សូមឲ្យក្រុមហ៊ុន ដោះស្រាយដីស្រែចម្ការដែលប៉ះពាល់របស់ប្រជាពលរដ្ឋ ភូមិគោក ក្នុងករណីដែលក្រុមហ៊ុនធ្វើការឈូសឆាយទៅដល់ |

| | | |
|---|---|---|
| | | - សូមឲ្យក្រុមហ៊ុន សាងសង់ហេដ្ឋារចនា-សម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវលំ អណ្តូងទឹក សាលារៀន មន្ទីរពេទ្យ.ល.។ |
| លោក ម៉ី ហន មេភូមិគោក (ការពិគ្រោះយោបល់លើកទី២) | - មិនប៉ះពាល់ដល់ដីក្នុងឃុំស្អាងទេ ប៉ុន្តែប៉ះពាល់ដល់ដីនៅឃុំតស៊ូ ដែលជាកម្មសិទ្ធរបស់ប្រជាពលរដ្ឋ ភូមិគោក ឃុំស្អាង<br>- ធ្លាប់មានការឈូសឆាយប៉ះពាល់ដីប្រជាពលរដ្ឋ ភូមិគោកដែលមានទីតាំងក្នុងឃុំតស៊ូ ប៉ុន្តែលោកមេភូមិមិនទាន់ទទួលបានព័ត៌មានថាមាន ប៉ុន្មានគ្រួសារ និងទំហំដីប៉ុន្មាននៅឡើយទេ<br>- នៅក្នុងភូមិគោក ក្រុមយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ មិនទាន់បានវាស់វែងនៅឡើយទេ | - សូមឲ្យក្រុមហ៊ុន ទុកដីដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋក្នុងភូមិគោក ដោយកុំឲ្យមានការឈូសឆាយ។ |
| លោក ជុំ គៀង មេឃុំពុទ្រា (ការពិគ្រោះយោបល់លើកទី១) | - លោកបានជ្រាប និងយល់ស្របនឹងគម្រោងវិនិយោគនេះ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋក្នុងភូមិពុទ្រា ភូមិបរ និងភូមិក្រាំងដែលជាឧបសម្ព័ន្ធរបស់ភូមិបរ ព្រមទាំងប៉ះពាល់ដីដែលលែងសត្វ។ | - សូមឲ្យក្រុមហ៊ុនជួយកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំដូចជា ស្ពាន ផ្លូវ សាលារៀន មន្ទីរពេទ្យ និងជាពិសេសសូមឲ្យក្រុមហ៊ុនជួយសាងសង់ ស្ពានអូរជ្រៃល និងសាលារៀននៅក្នុងភូមិបរ។<br>. សូមឲ្យក្រុមហ៊ុនសហការណ៍ល្អ ជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។<br>. សូមឲ្យក្រុមហ៊ុនកាត់ចេញនូវដី ដែលប៉ះពាល់ច្រើនជាមួយប្រជាពលរដ្ឋ។<br>. បើក្រុមហ៊ុនសិក្សា បង្ហាញថាផលប៉ះពាល់ច្រើនហើយដីក្រុមហ៊ុននូវសល់តិច។ |
| លោក ជុំ គៀង មេឃុំពុទ្រា (ការពិគ្រោះយោបល់លើកទី២) | - នៅក្នុងឃុំពុទ្រា ក្រុមហ៊ុនមិនទាន់ធ្វើការឈូសឆាយមកដល់នៅឡើយទេ។<br>- ភូមិដែលពាក់ព័ន្ធ ជាមួយក្រុមហ៊ុនគឺ ភូមិបរ និងភូមិពុទ្រា ហើយបច្ចុប្បន្ននេះ គឺក្រុមហ៊ុនបានសាងសង់ផ្លូវកាត់ ភូមិ ក្នុងភូមិសាស្ត្រភូមិបរ។<br>- ក្រុមហ៊ុនបានវាស់វែងលើដីបំរុងទុកសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅក្នុងឃុំរួចហើយ ដែលមានទំហំប្រហែល ១០០ ហិកតា។ | - សូមឲ្យក្រុមហ៊ុនយកកម្លាំងពលកម្មក្នុងភូមិឃុំ ទៅបម្រើការងារក្នុងទីតាំងគម្រោង។ |
| លោក សុក ភាព មេភូមិបរ (ការពិគ្រោះយោបល់លើកទី១) | - លោកធ្លាប់បានដឹង និងពុំជំទាស់នឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុនខាងលើនេះទេ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ នៅក្នុងភូមិបរ និងភូមិក្រាំងដែលជាឧបសម្ព័ន្ធរបស់ភូមិបរ | - សូមឲ្យក្រុមហ៊ុនជួយកសាងស្ពានឆ្លងកាត់អូរជ្រៃល។<br>- សូមឲ្យក្រុមហ៊ុនជួយសាងសង់សាលារៀននៅក្នុងភូមិបរ។ |

Draft

| | | |
|---|---|---|
| | | - សូមឲ្យក្រុមហ៊ុនកាត់ចេញនូវដីស្រែចម្ការដែលប៉ះពាល់ជាមួយប្រជាពលរដ្ឋ។<br>- សូមឲ្យក្រុមហ៊ុនសហការណ៍ល្អជាមួយប្រជាពលរដ្ឋ និងអជ្ញាធរ។<br>- បើសិនក្រុមហ៊ុនសិក្សាឃើញថា ផលប៉ះ-ពាល់ដីស្រែចម្ការប្រជាពលរដ្ឋច្រើន ហើយដីក្រុមហ៊ុននៅសល់តិច សូមឲ្យក្រុមហ៊ុនកាត់ជូនប្រជាពលរដ្ឋ។ |
| លោក សុក ភាព មេភូមិបរ (ការពិគ្រោះយោបល់លើកទី ២) | - នៅក្នុងភូមិបរក្រុមហ៊ុនកំពុងតែសាងសង់ផ្លូវកាត់ភូមិ ហើយក៏បានដោះស្រាយជាមួយប្រជាពលរដ្ឋដែលមានការប៉ះពាល់ជាមួយផ្លូវដែលកំពុងសាងសង់។ ចំពោះដីដែលមានបណ្ណ័កម្មសិទ្ធ ក្រុមហ៊ុនបានទូទាត់ជាសំណងជូន ប៉ុន្តែបើដីនោះមិនមានបណ្ណ័កម្មសិទ្ធទេនិងចាត់ទុកជាដីរដ្ឋ<br>- បច្ចុប្បន្នប្រជាពលរដ្ឋមានការព្រួយបារម្ភដែលក្រុមហ៊ុនអាចឈូសឆាយប៉ះពាល់ដល់ដីរបស់គាត់។ | - សូមឲ្យក្រុមហ៊ុនជួយសាងសង់ផ្លូវនៅក្នុងភូមិ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ |
| លោក យុត ចេន មេភូមិពុទ្រា (ការពិគ្រោះយោបល់លើកទី១) | - លោកធ្លាប់បានជ្រាប និងពុំជំទាស់នឹងគម្រោងវិនិយោគនេះទេ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋនៅក្នុងភូមិពុទ្រា ចំនួន ១០១គ្រួសារ ដែលក្នុងនោះ ផ្ទៃដីស្រែសរុប ២៨២ហិកតា និងផ្ទៃដីចម្ការសរុប ៣៣៨ហិកតា។ | - សូមឲ្យក្រុមហ៊ុន ដោះស្រាយផលប៉ះពាល់របស់ប្រជាពលរដ្ឋភូមិពុទ្រាជាមុនសិន មុននឹងដំណើរការឈូសឆាយ។<br>- សូមឲ្យក្រុមហ៊ុន ជួយអភិវឌ្ឍន៍ហេដ្ឋា-រចនាសម្ព័ន្ធមូលដ្ឋានដូចជា ផ្លូវលំ សាលារៀន មន្ទីរពេទ្យ អណ្តូងទឹក។ |
| លោក យុត ចេន មេភូមិពុទ្រា (ការពិគ្រោះយោបល់លើកទី២) | - នៅក្នុងភូមិពុទ្រា មិនទាន់មានផលប៉ះពាល់អ្វីជាមួយក្រុមហ៊ុនទេ ដោយក្រុមហ៊ុនធ្លាប់ចុះសិក្សាដល់ទីតាំងផ្ទាល់ ទោះបីជាគ្មានបញ្ហាអ្វីនៅឡើយ តែវាអាចប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ។ | - សូមឲ្យក្រុមហ៊ុនសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីជួយធ្វើបណ្ណ័កម្មសិទ្ធដីធ្លីជូនប្រជាពលរដ្ឋ ដែលមានដីពាក់ព័ន្ធនិងក្រុមហ៊ុន។ |
| លោក ព្រុំ កើន មេឃុំតស៊ូ (ការពិគ្រោះយោបល់លើកទី១) | - លោកមេឃុំធ្លាប់បានជ្រាប និងយល់ស្របនឹងគម្រោងវិនិយោគនេះ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋរបស់ភូមិតស៊ូ និងភូមិសំពេង ប៉ុន្តែដីដែលប៉ះពាល់ក្រុមហ៊ុនគឺ ក្រុមយុវជនស្ម័គ្រចិត្តសម្តេចតេជោបានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋរួចហើយ។ | - សូមឲ្យក្រុមហ៊ុនសហការល្អជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរក្នុងតំបន់<br>- សូមឲ្យក្រុមហ៊ុនកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជា ផ្លូវ សាលារៀន មន្ទីរពេទ្យ អណ្តូងទឹក វត្តអារាម.ល.។ |
| លោក ព្រុំ កើន មេឃុំតស៊ូ | - ប៉ះពាល់ដីស្រែ ចម្ការ របស់ភូមិតស៊ូ ភូមិសំពេង | - សូមឲ្យក្រុមហ៊ុនដោះស្រាយផលប៉ះពាល់ |

Draft

| | | |
|---|---|---|
| (ការពិគ្រោះយោបល់លើកទី២) | និងភូមិថ្មី ប៉ុន្តែលោកមិនទាន់ក្ដាប់បាននូវចំនួនគ្រួសារ និងទំហំផ្ទៃដីនៅឡើយទេ<br>- លោកមេឃុំកំពុងតែរង់ចាំដំណោះស្រាយពីថ្នាក់ស្រុក ថ្នាក់ខេត្ត និងស្ថាប័នជំនាញពាក់ព័ន្ធ | ជាមួយប្រជាពលរដ្ឋឲ្យផាប់ហើយ ដើម្បីកុំឲ្យមានទំនាស់តទៅទៀត។ |
| លោក ព្រំ សោន ក្រុមប្រឹក្សាឃុំតស៊ូតំណាងភូមិសំពេង (ការពិគ្រោះយោបល់លើកទី១) | - លោកមេឃុំធ្លាប់បានជ្រាប និងពុំជំទាស់នឹងគម្រោងវិនិយោគនេះទេ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋរបស់ភូមិសំពេង ប្រហែល ៧០គ្រួសារ ប៉ុន្តែក្រុមយុវជនស្ម័គ្រចិត្តសម្ដេចតេជោ បានចុះវាស់វែងដីធ្លី និងចែកប័ណ្ណកម្មសិទ្ធិ ជូនប្រជាពលរដ្ឋភូមិសំពេងរួចរាល់ហើយ។ | - សូមឲ្យក្រុមហ៊ុនសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវលំក្នុងភូមិ ស្ពាន សាលារៀន មន្ទីរពេទ្យ អណ្ដូងទឹក.ល.។ |
| លោក ថោង លឿត មេភូមិសំពេង (ការពិគ្រោះយោបល់លើកទី២) | - មានការប៉ះពាល់ដល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋច្រើនគួរសមដែរ។<br>- មានការចូលរួមដោះស្រាយពីសំណាក់គណៈកម្មការមួយចំនួនដូចជា មន្ទីរសុរិយោដី មន្ទីរកសិកម្មស្រុក និងអាជ្ញាធរដែនដីដែលពាក់ព័ន្ធមួយចំនួនទៀតតែពុំទាន់រួចរាល់នៅឡើយទេ។ លោកមេភូមិកំពុងរង់ចាំការដោះស្រាយពីថ្នាក់ខេត្ត។ | - សុំឲ្យក្រុមហ៊ុនធ្វើការឈូសឆាយដីដោយទុកព្រៃខ្លះពីដីរបស់ប្រជាពលរដ្ឋ<br>- ផ្ដល់អទិភាពខ្ពស់ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ ដើម្បីធ្វើជាកម្មករនៅក្នុងក្រុមហ៊ុន។ |
| លោក អ៊ុច តែន មេភូមិតស៊ូ (ការពិគ្រោះយោបល់លើកទី១) | - លោកមេភូមិធ្លាប់បានដឹង និងពុំជំទាស់នឹងគម្រោងវិនិយោគនេះទេ។<br>- ប៉ះពាល់ដីស្រែចម្ការ របស់ប្រជាពលរដ្ឋនៅក្នុងគម្រោង ប៉ុន្តែត្រូវបានក្រុមយុវជនស្ម័គ្រចិត្តសម្ដេចតេជោ បានវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិរួចហើយ | - សូមឲ្យក្រុមហ៊ុន ជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវ ស្ពាន អណ្ដូងទឹក សាលារៀន.ល.។ |
| លោក អ៊ុច តែន មេភូមិតស៊ូ (ការពិគ្រោះយោបល់លើកទី២) | - មានដីរបស់ប្រជាពលរដ្ឋប្រហែលជា៩០គ្រួសារ ដែលពាក់ព័ន្ធនឹងក្រុមហ៊ុន តែមិនទាន់ធ្វើការឈូសឆាយ ទៅដល់នៅឡើយ<br>- អាចនឹងមានការប៉ះពាល់ដល់ដីលែងសត្វរបស់ប្រជាពលរដ្ឋ<br>- ប្រជាពលរដ្ឋមានការព្រួយបារម្ភចំពោះការឈូសឆាយអាចនឹងប៉ះពាល់ដល់ដីរបស់ពួកគាត់<br>- មានការពិបាកក្នុងការធ្វើដំណើរ | - សូមឲ្យក្រុមហ៊ុនកុំមានការឈូសឆាយជាលក្ខណៈស្បែកខ្លា តែក្រុមហ៊ុនអាចធ្វើការឈូសឆាយព្រៃនៅខាងជើងភូមិបាន។ |
| ខ. ស្ថាប័ន និងមន្ទីរជំនាញពាក់ព័ន្ធ | | |
| លោក ខូយ យុនចន្ទរ័ត្ន ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ | - លោកប្រធានធ្លាប់បានជ្រាប និងគាំទ្រចំពោះគម្រោងវិនិយោគនេះ។<br>- ប៉ះពាល់ដីស្រែ និងមនុស្សជំនាន់ក្រោយ និងសតិអារម្មណ៍របស់ពួកគាត់។<br>- ប៉ះពាល់ធនធានធម្មជាតិ អាចបាត់បង់ដីចម្រុះ | - សូមឲ្យក្រុមហ៊ុន អនុវត្តតាមកិច្ចសន្យាជាមួយរដ្ឋាភិបាលឲ្យបានម៉ត់ចត់។<br>- សូមឲ្យក្រុមហ៊ុនរក្សាព្រៃស្រោង ដែលមាននៅក្នុងក្រុមហ៊ុន។ |

Draft

| | | |
|---|---|---|
| | សត្វព្រៃ និងជម្រកសត្វ អាចប្រែប្រួលទម្រង់បឹងធម្មជាតិ។ | - សូមឲ្យក្រុមហ៊ុន រក្សាព្រៃទ្រនាប់ដងអូរ ត្រពាំង បឹងធម្មជាតិ។<br>- សូមឲ្យក្រុមហ៊ុនទុកឲ្យប្រជាពលរដ្ឋចេញចូលប្រកបរបរក្នុងក្រុមហ៊ុន ចំពោះអ្នកដែលមានដីនៅក្នុង។<br>- សូមឲ្យក្រុមហ៊ុនជួយមើលការលំបាក និងអភិវឌ្ឍន៍ក្នុងសហគមន៍។<br>- ពាក់ពន្ធនឹងពូជអំពៅដែលឆ្លងដែន សូមឲ្យមានការឯកភាព ពីមន្ទីរជំនាញបរិស្ថានសំខាន់សូមឲ្យមានច្បាប់នាំចូល។<br>- សូមឲ្យក្រុមហ៊ុន កុំឲ្យប៉ះពាល់ដីរបស់ប្រជាពលរដ្ឋទោះបីរាស់ហើយ និងមិនទាន់រាស់ហើយក៏ដោយ។ |
| លោក ស្រ៊ុន បូរិទ្ធ<br>អនុប្រធានមន្ទីរ<br>កសិកម្មខេត្តព្រះវិហារ<br>(ការពិគ្រោះយោបល់លើកទី១) | - លោកអនុប្រធានមន្ទីរធ្លាប់បានជ្រាប និងឯកភាពនឹងគម្រោងអភិវឌ្ឍន៍នេះ។<br>- ប៉ះពាល់ដើមជ័រច្បោះរបស់ប្រជាពលរដ្ឋ<br>- ប៉ះពាល់ធនធានធម្មជាតិ (អូរ បឹង ស្ទឹង ។ល។)<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋ | - សូមឲ្យក្រុមហ៊ុនកំណត់ព្រំ របស់ក្រុម-ហ៊ុនជាមួយប្រជាពលរដ្ឋ ឲ្យបានច្បាស់-លាស់។<br>- សូមឲ្យក្រុមហ៊ុនដោះស្រាយ នៅពេលដែលក្រុមហ៊ុនឈូសឆាយ ប៉ះពាល់ដើមច្បោះជ័ររបស់ប្រជាពលរដ្ឋ។<br>- សូមឲ្យក្រុមហ៊ុនផ្សព្វផ្សាយ ឲ្យបានទូលាយពីការធ្វើកសិកម្មតាមកិច្ចសន្យា<br>- សូមឲ្យក្រុមហ៊ុន រក្សាទុកតំបន់អារក្សកន្លែងលែងសត្វ ទីជំនឿសាសនា បឹង អូរ |
| លោក ស្រ៊ុន បូរិទ្ធ<br>អនុប្រធានមន្ទីរ<br>កសិកម្មខេត្តព្រះវិហារ<br>(ការពិគ្រោះយោបល់លើកទី២) | - លោកបានជ្រាប និងឯកភាពនឹងគម្រោងវិនិយោគខាងលើនេះ។<br>- អាចនឹងបង្កឲ្យខូចគុណភាពដី និងគុណភាពដី ប្រសិនបើក្រុមហ៊ុនមិនបានប្រើប្រាស់តាមបច្ចេកទេស។ | - សូមក្រុមហ៊ុនសហការល្អរវាងអជ្ញាធរ និងមន្ទីរពាក់ព័ន្ធ<br>- សូមក្រុមហ៊ុនមានការអនុគ្រោះដល់ដីប្រជាជនឲ្យបានច្រើន<br>- មន្ទីរកសិកម្មមានផែនការ និងបានផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ដំណាំអំពៅដោយធ្វើការប្រៀបធៀប ដំណាំអំពៅ និងស្រូវ រយៈពេល១ឆ្នាំ ១ហិកតា ជាលទ្ធផលគឺដំណាំអំពៅមានប្រសិទ្ធភាពខ្ពស់ជាងដំណាំស្រូវ។ |
| លោក គង់ មករា ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តព្រះវិហារ | - លោកធ្លាប់បានជ្រាប និងពុំជំទាស់ចំពោះគម្រោងអភិវឌ្ឍន៍នេះទេ។ | - សូមឲ្យក្រុមហ៊ុនជ្រើសរើសពលកម្ម ក្នុងមូលដ្ឋានទៅបម្រើការងារ ក្នុងទីតាំង |

Draft

| | | |
|---|---|---|
| | - ប៉ះពាល់លើទៅលើក្រុមហ៊ុនរុករករ៉ែរបស់ក្រុមហ៊ុន Mekong Mining ប៉ុន្តែក្រុមហ៊ុននេះពុំទាន់ធ្វើដំណើរ ការរបស់ខ្លួននៅឡើយទេ។<br>- ប៉ះពាល់ទៅលើដីស្រែចម្ការរបស់ប្រជាពលរដ្ឋ។ | គម្រោង និងជួយបង្រៀនបច្ចេកទេសដល់ប្រជាពលរដ្ឋ។<br>- សូមឲ្យក្រុមហ៊ុន គោរពតាមកិច្ចសន្យាដែលក្រុមហ៊ុនបានធ្វើជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>- សូមឲ្យក្រុមហ៊ុនគោរពប្រពៃណី វប្បធម៌របស់ជនជាតិដើមភាគតិច។<br>- ចំពោះការប៉ះពាល់ទៅលើក្រុមហ៊ុនរុករករ៉ែ សុំឲ្យក្រុមហ៊ុន អនុវត្តន៍តាមគោលការណ៍សម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ |
| លោក សរ សាវេត អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ<br>(ការពិគ្រោះយោបល់លើកទី ១) | - លោកបានជ្រាប និងពុំជំទាស់លើគម្រោងវិនិយោគនេះទេ។<br>- ប៉ះពាល់ដីស្រែចម្ការរបស់ប្រជាពលរដ្ឋក្នុងឃុំតស៊ូ និងឃុំស្អាង ប៉ុន្តែក្រុមយុវជនស្ម័គ្រចិត្ត សម្តេចតេជោ បានចុះវាស់វែង និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋរួចរាល់ហើយ ។ | - សូមឲ្យក្រុមហ៊ុន សហការណ៍ល្អជាមួយមន្ទីរដែនដីខេត្តព្រះវិហារក្នុងការសោងសង់សំណង់ក្នុងទីតាំងគម្រោង។<br>- សូមឲ្យខាងក្រុមហ៊ុនមកកាត់ឈ្មោះ ប្លង់ដីដែលបានដោះដូរ (ទិញ) ពីប្រជាពលរដ្ឋរួចជៀសវាងមានទំនាស់នៅថ្ងៃក្រោយ។ |
| លោក គង់ សោភ័ណ ប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តព្រះវិហារ<br>(ការពិគ្រោះយោបល់លើកទី ២) | - លោកបានជ្រាប និងឯកភាពនឹងគម្រោងវិនិយោគនេះ។<br>- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីបានចុះបញ្ជីដីធ្លីក្នុងភូមិសំរោង ចំនួន ១៤ក្បាលដី ស្មើនឹង៦៧ហិកតា។ ស្រុកត្បែងមានជ័យចំនួន ៤០៤ ក្បាលដី បានវាសវែងរួច និងកាត់ហើយចំនួន ៥១ គ្រួសារ។ | - សូមឲ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យារវាងក្រុមហ៊ុន និងអ្នកពាក់ព័ន្ធផ្សេងៗ<br>- សូមឲ្យក្រុមហ៊ុនជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ដូចជា: សាលារៀន ផ្លូវ អណ្តូងទឹក វត្តអារាម បន្ទាប់ពីក្រុមហ៊ុនបានដំណើរការ |
| លោក ចាប កុយ ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រះវិហារ | - លោកប្រធានធ្លាប់បានជ្រាប និងពុំជំទាស់ទៅនឹងគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុននេះទេ។ | - សូមឲ្យក្រុមហ៊ុនរក្សាព្រៃទ្រនាប់ដងអូរ ៧០ភាគរយ ក្នុងគម្រោង<br>- សូមឲ្យក្រុមហ៊ុនរក្សា អូរ បឹង ចាស់ៗក្នុងគម្រោង។ |

Draft

| | | |
|---|---|---|
| លោក នៅ សុគុណ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តព្រះវិហារ (ការពិគ្រោះយោបល់លើកទី១) | - លោកប្រធានធ្លាប់បានជ្រាប និងពុំជំទាស់ចំពោះគម្រោងដីសម្បទានសេដ្ឋកិច្ចទេ ហើយម្យ៉ាងទៀតវាគ្មានអ្វីពាក់ព័ន្ធ ចំពោះការដាំដំណាំនេះទេ។ | - ពេលដែលឈូសឆាយ បើសិនបានជួបប្រទះនូវគ្រឹះប្រាសាទ ទួល ស្រះ ឡស្លដែក...។<br>- សូមឲ្យខាងក្រុមហ៊ុនវិនិយោគរាយការណ៍មកមន្ទីរជាបន្ទាន់ ដើម្បីមន្ទីរចុះទៅសិក្សាកំណត់ព្រំដីនៅទីនោះ ហើយកុំឲ្យវាមានបាតុភាពអ្វីមួយកើតមានឡើងហើយ ទើបរាយការណ៍ប្រាប់មន្ទីរ។ |
| លោក សំ លាងទ្រី ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ | - លោកបានជ្រាប និងឯកភាព នឹងគម្រោងវិនិយោគខាងលើនេះ។<br>- អ្នកបើកបរ ឬអ្នកដឹកអំពៅក្មេងៗពេក និងបើកបរលឿនហួសកំណត់<br>- ការដឹកអំពៅរបស់ក្រុមហ៊ុន គឺធ្លាក់រប៉ាតរប៉ាយពេញផ្លូវ ប៉ុន្តែមិនបានដឹកលើសទំងន់ទេ អ្វីដែលជាបញ្ហា គឺដឹកសំពីងសំពោង<br>- ក្រុមហ៊ុនធ្លាប់ដឹកសម្ភារៈ គ្រឿងចក្រ ខ្សាច់ ថ្មលើសទំងន់<br>- ក្រុមហ៊ុន ធ្លាប់បានបុកស្លាកសញ្ញាជំមួយនៅស្រុកឆែប។ | - សូមឲ្យក្រុមហ៊ុនអនុវត្តដំណើការរបស់ខ្លួនតាមផែនការមេ និងកិច្ចសន្យាដែលបានធ្វើជាមួយរដ្ឋាភិបាល<br>មានគម្រោងសាងសង់ស្ពាននៅឃុំកំពុងស្រឡៅ ស្រុកឆែប ខេត្តព្រះវិហារ ដោយឆ្លងកាត់ទន្លេល្ពៅ តភ្ជាប់ទៅប្រទេសឡាវ និងបើកច្រកអន្តរជាតិជំមួយ។ |
| លោក សេង សារី ប្រធានមន្ទីរអភិវឌ្ឍជនបទខេត្តព្រះវិហារ | - លោកធ្លាប់បានជ្រាប និងឯកភាពនឹងគម្រោងវិនិយោគខាងលើនេះ ព្រោះគម្រោងបានជួយអភិវឌ្ឍដល់សហគមន៍មូល និងកាត់បន្ថយភាពក្រីក្រ។ | - សូមឲ្យក្រុមហ៊ុនសហការល្អជាមួយមន្ទីរ និងអាជ្ញាធរពាក់ព័ន្ធ<br>- សូមឲ្យក្រុមហ៊ុនជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានដូចជាៈ សាលារៀន ផ្លូវលំ វត្តអារាម អណ្តូងទឹក ពិសេសទឹកស្អាត<br>- មុនពេលឈូសឆាយដីព្រៃ សូមឲ្យក្រុមហ៊ុនរាយការណ៍ និងសហការល្អដល់អាជ្ញាធរ និងមន្ទីរពាក់ព័ន្ធ<br>- សូមឲ្យក្រុមហ៊ុនមានផែនការអនុវត្តច្បាស់លាស់ ដើម្បីឲ្យមន្ទីរពាក់ព័ន្ធចូលរួមឆ្លងយោបល់ និងវាយតម្លៃលើបទដ្ឋានគតិយុទ្ធ។ |
| លោក ហេង កុយ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - លោកប្រធានបានជ្រាប និងឯកភាពគម្រោងវិនិយោគខាងលើនេះ ព្រោះគម្រោងជួយលើកមុខមាត់ប្រទេសកម្ពុជា។ | - សូមឲ្យក្រុមហ៊ុនផ្តល់ជាអាហារូបករណ៍ដល់មន្ត្រីរបស់មន្ទីរការងារ ដើម្បីបានបន្តការសិក្សានៅប្រទេសចិន អីពីច្បាប់ |

| | | |
|---|---|---|
| ខេត្តព្រះវិហារ | | ឬផ្នែកកសិកម្មជាដើម<br>- សូមឲ្យក្រុមហ៊ុនបន្តក្នុងការបញ្ជូនកម្មករទៅរៀនពីបច្ចេកទេសថ្មីៗពីបរទេស។ |
| លោក នង ខេមរិន្ទ នាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ (ការពិគ្រោះយោបល់លើកទី១) | - លោកធ្លាប់បានជ្រាបពីគម្រោង តាំងពីមុនមក តាមរយៈលិខិតបទដ្ឋានដែលរាជរដ្ឋាភិបាលបានអនុញ្ញាត លិខិត២២៩ សជណ/២៨/០២/២០១១ ។ | - សូមឲ្យក្រុមហ៊ុនរក្សាទុកតំបន់ព្រៃ ដែលមានកំណត់ក្នុងកិច្ចសន្យាឲ្យបាន។<br>- ក្រុមហ៊ុន ត្រូវធ្វើការឈូសឆាយឆ្លាស់គ្នា ដើម្បីឲ្យសត្វមានឱកាសផ្លាស់ប្តូរទីកន្លែងរស់នៅ។<br>- ក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះក្រុមហ៊ុនឈូសឆាយដែលតែងតែឈូសឆាយដល់មាត់អូរ បឹង...។<br>- សូមឲ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យាដែលបានធ្វើជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>- សូមឲ្យក្រុមហ៊ុន សហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានជាប្រចាំ ពេលអនុវត្តការឈូសឆាយ តាមលិខិតអនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>- សូមឲ្យក្រុមហ៊ុនដាំសងវិញ ចំពោះអ្វីដែលបានឈូសឆាយជ្រុលជ្រួសកន្លងមក ករណីជូននាំទៅតាមមាត់ស្ទឹង បឹងធម្មជាតិ។<br>- រាល់ការប្រមូលផល (សំណល់) ឲ្យអស់លទ្ធភាពមុនធ្វើការដុតកម្ទេច។<br>- មុនដុតកម្ទេចកាកសំណល់ចុងក្រោយ ត្រូវធ្វើលិខិតមករដ្ឋបាលព្រៃឈើ មានសមត្ថកិច្ច ដើម្បីធ្វើការវាយតម្លៃជាមុនដាច់ខាត។<br>- មិនអនុញ្ញាតឲ្យក្រុមហ៊ុនឈូសឆាយព្រៃដោយគ្មានលិខិតអនុញ្ញាតដាច់ខាត។ |
| លោក នង ខេមរិន្ទ នាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ (ការពិគ្រោះយោបល់លើកទី២) | - នៅមានបញ្ហាដីធ្លីមួយចំនួននៅឡើយ ប៉ុន្តែគណៈកម្មាធិការដោះស្រាយដីធ្លី និងក្រុមហ៊ុនវិនិយោគនៅតែបន្តដោះស្រាយបន្តទៀត។<br>- បញ្ហាដីធ្លីនេះកើតមានឡើងដោយសារតែមានជនអគតិមួយចំនួននៅពីក្រោយខ្នង មិនព្រមទទួលយកដំណោះស្រាយ និងការឈូសឆាយរបស់ក្រុមហ៊ុនក៏មានបញ្ហាដោយសារការជួលភាគីទី២ ក្នុងការឈូសឆាយ ហើយភាគីទី២ | - សូមឲ្យក្រុមហ៊ុនជួយថែរក្សាការពារព្រៃក្បោទុកដែលមានដូចជាព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃការពារតាមទ្រនាប់ផ្លូវទឹក។<br>- សូមឲ្យក្រុមហ៊ុនធ្វើការប្រមូលកាកសំណល់ដែលឈូសឆាយហើយដើម្បីបង់ពន្ធជូនរដ្ឋ ដោយមានការសហការជាមួយរដ្ឋបាលព្រៃឈើ ឲ្យអស់លទ្ធភាព។ |

Draft

| | | |
|---|---|---|
| | នោះធ្វើការជួលបន្តទៅភាគីផ្សេងទៀតដែលជាហេតុធ្វើឲ្យមានលក្ខណៈខុសបច្ចេកទេស (ករណីឈូសចូលព្រៃរក្សាទុកជាដើម)<br>- ថ្មីៗនេះខាងក្រុមហ៊ុនបានធ្វើការឈូសឆាយដីព្រៃ ប៉ុន្តែមិនបានដកហូតឈើហ៊ុបមកបង់ពន្ធទេ ដោយក្រុមហ៊ុនបានធ្វើការដុតឈើ ដែលឈូសឆាយចោល ហើយខាងជំនាញរដ្ឋបាលព្រៃឈើតែងតែចុះធ្វើការណែនាំពីបញ្ហានេះ។ | - ក្រុមហ៊ុនត្រូវអនុវត្តទៅតាមផែនការមេដែលមានចែងក្នុងកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល។ |
| លោក ប៉ែន វាសនា នាយខណ្ឌរដ្ឋបាលជលផលព្រះវិហារ (ការពិគ្រោះយោបល់លើកទី១) | - លោកពុំធ្លាប់បានជ្រាប និងពុំជំទាស់នឹងគម្រោងវិនិយោគខាងលើនេះទេ។<br>- ប៉ះពាល់ទៅលើការហូរច្រោះដី<br>- ប៉ះពាល់ទឹកដោយសារការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- បាត់បង់ជម្រកត្រី និងប្រភពចំណីអាហាររស់វា<br>- បាត់បង់នូវគម្របដីខាងលើដែលធ្វើឲ្យប្រែប្រួលនូវលក្ខណៈជីវសាស្ត្រអូរ។ | - សូមឲ្យក្រុមហ៊ុនរាយការណ៍មកខណ្ឌរដ្ឋបាលជលផល ចំពោះការជីកប្រឡាយក្នុងតំបន់គម្រោង។ |
| លោក អេង គីមឡេង នាយរងខណ្ឌរដ្ឋបាលជលផលព្រះវិហារ (ការពិគ្រោះយោបល់លើកទី២) | - លោកបានជ្រាបពីវត្តមានគម្រោង នេះពីមុនមកតាមរយៈការចុះអង្កេតរបស់ខណ្ឌរដ្ឋបាលជលផល។ ទីតាំងគម្រោងមានប្រភេទត្រីដូចជាត្រីឆ្តោង ត្រីខ្ចឹង ត្រីឆ្លូញ ត្រីអណ្តែង ត្រីរ៉ស់ ត្រីក្រពាត់ ត្រីក្អែក ត្រីដំរី និងត្រីកញ្ចុះថ្ម... ហើយខណ្ឌរដ្ឋបាលជលផលទើបតែចុះទៅសិក្សាអំពីហេតុប៉ះពាល់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ឃើញថាមានផលប៉ះពាល់តិចតួចប៉ុណ្ណោះពីសំណាក់បុគ្គលិក-កម្មកររបស់គម្រោង។ | - សូមឲ្យក្រុមហ៊ុនរក្សាទុកតំបន់ដែលមានទឹកជ្រៅ<br>- សូមឲ្យរក្សាទុកអូរធំៗ បឹងធម្មជាតិ កន្លែងអភិរក្ស ស្រះទឹកសហគមន៍<br>- សូមឲ្យក្រុមហ៊ុនជួយលែងកូនត្រីនៅក្នុងទីតាំងគម្រោង |

## ៦.៥ សន្និដ្ឋានរួម

❖ មតិយោបល់ របស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន

តាមរយៈការសម្ភាសន៍ជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ទាក់ទងទៅនឹងគម្រោងវិនិយោគរបស់ក្រុមហ៊ុន ហេង ណុង បានបង្ហាញឲ្យឃើញថា ពួកគាត់មានការគាំទ្រចំពោះវត្តមានគម្រោងវិនិយោគ ១០០% ពីព្រោះវាបានជួយអភិវឌ្ឍភូមិ ឃុំ និងប្រទេសជាតិ ឲ្យមានការរីកចម្រើន ហើយស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ ប៉ុន្តែបើក្នុងករណីដែលក្រុមហ៊ុនមិនគោរពតាមគោលការណ៍ និងកិច្ចសន្យាដែលបានធ្វើជាមួយរាជរដ្ឋាភិបាល ព្រមទាំងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ និងធនធានក្នុងតំបន់ អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធនឹងសហការចុះទៅធ្វើការពិនិត្យតាមដាន និងវាយតម្លៃពីហេតុប៉ះពាល់ដែលបង្កដោយគម្រោង ដើម្បីរៀបចំជារបាយការណ៍សម្រាប់បញ្ជូនទៅថ្នាក់លើធ្វើការពិនិត្យ និងពិចារណាលើលទ្ធភាពក្នុងការបញ្ឈប់ ឬអនុញ្ញាតឲ្យដំណើរការបន្ត។



Draft

❖ ហេតុប៉ះពាល់សំខាន់ៗ

- នៅក្នុងភូមិស្អាងមានដីប៉ះពាល់ជាមួយក្រុមហ៊ុន គឺមានតិចតួចប៉ុណ្ណោះ។ អ្នកស្រីមេភូមិមិនអាចក្តាប់ព័ត៌មានពីចំនួនគ្រួសារ និងទំហំដីរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ជាមួយក្រុមហ៊ុនទេ។
- ធ្លាប់មានការឈូសឆាយប៉ះពាល់ដីប្រជាពលរដ្ឋនៅក្នុងភូមិគោក ដែលមានទីតាំងក្នុងឃុំតស៊ូ ប៉ុន្តែលោកមេភូមិមិនទាន់ទទួលបានព័ត៌មានច្បាស់នៅឡើយទេ។
- នៅក្នុងភូមិបរ ក្រុមហ៊ុនកំពុងតែសាងសង់ផ្លូវកាត់ភូមិហើយក៏បានដោះស្រាយ ជាមួយប្រជាពលរដ្ឋ ដែលមានការប៉ះពាល់ជាមួយផ្លូវដែលកំពុងសាងសង់។ ចំពោះដីដែលមានបណ្ណ័កម្មសិទ្ធ ក្រុមហ៊ុនបានទូទាត់ជាសំណងជូន ប៉ុន្តែបើដីនោះមិនមានបណ្ណ័កម្មសិទ្ធទេនិងចាត់ទុកជាដីរដ្ឋ
- ចំពោះនៅក្នុងភូមិពុទ្រា មិនទាន់មានផលប៉ះពាល់អ្វីជាមួយក្រុមហ៊ុនទេ ប៉ុន្តែវាអាចប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ។
- ភូមិតស៊ូមានដីរបស់ប្រជាពលរដ្ឋប្រហែលជា៩០គ្រួសារ ដែលពាក់ព័ន្ធនឹងក្រុមហ៊ុន តែមិនទាន់ធ្វើការឈូសឆាយទៅដល់នៅឡើយ។
- អាចនឹងមានការប៉ះពាល់ដល់ដីវែលសត្វរបស់ប្រជាពលរដ្ឋ
- អាចនឹងបង្កឲ្យខូចគុណភាពដី និងគុណភាពដី ប្រសិនបើក្រុមហ៊ុនមិនបានប្រើប្រាស់តាមបច្ចេកទេស
- ក្រុមហ៊ុនមិនទាន់បង្កផលប៉ះពាល់ជុំវិញទីតាំងគម្រោងនៅឡើយ ពិសេស ផ្លូវលំ និងទឹកស្អាត
- ថ្មីៗនេះខាងក្រុមហ៊ុនបានធ្វើការឈូសឆាយដីព្រៃ ប៉ុន្តែមិនបានដកហូតឈើហ៊ុបមកបង់ពន្ធទេ ដោយក្រុមហ៊ុនបានធ្វើការដុតឈើនោះទាំងអស់។ អ្នកជំនាញរបស់រដ្ឋបាលព្រៃឈើ បានចុះធ្វើការណែនាំពីបញ្ហានេះជបន្តបន្ទាប់។
- មានផលប៉ះពាល់តិចតួចចំពោះមច្ឆជាតិ ពីសំណាក់បុគ្គលិក-កម្មកររបស់គម្រោង។

❖ សំណូមពររបស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន

តាមរយៈការពិគ្រោះយោបល់ឃើញថា ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានសំណូមពរដល់ក្រុមហ៊ុនដូចជា:

- សុំឲ្យក្រុមហ៊ុនជួយសាងសង និងជួសជុលហេដ្ឋារចនាសម្ព័នដូចជាផ្លូវថ្នល់ សាលារៀន អណ្តូងទឹក និងវត្តអារាម។
- សូមឲ្យក្រុមហ៊ុន ទុកដីដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋក្នុងភូមិគោក ដោយកុំឲ្យមានការឈូសឆាយ។
- សូមឲ្យក្រុមហ៊ុនសហការជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ ជួយធ្វើបណ្ណ័កម្មសិទ្ធដីធ្លីជូនប្រជាពលរដ្ឋ ដែលមានដីពាក់ព័ន្ធនិងក្រុមហ៊ុន។
- សុំឲ្យក្រុមហ៊ុនធ្វើការឈូសឆាយដីដោយទុកព្រៃខ្លះពីដីរបស់ប្រជាពលរដ្ឋ
- ផ្តល់អទិភាពខ្ពស់ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ ដើម្បីធ្វើជាកម្មករនៅក្នុងក្រុមហ៊ុន។
- មន្ទីរកសិកម្មមានផែនការ និងបានផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ដំណាំអំពៅដោយធ្វើការប្រៀបធៀបដំណាំអំពៅ និងស្រូវ រយៈពេល១ឆ្នាំ ១ហិកតា ជាលទ្ធផលគឺដំណាំអំពៅមានប្រសិទ្ធភាពខ្ពស់ជាងដំណាំស្រូវ។
- សូមឲ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យារវាងក្រុមហ៊ុន និងអ្នកពាក់ព័ន្ធផ្សេងៗ
- សូមក្រុមហ៊ុនជួយណែនាំដល់ក្រុមហ៊ុនម៉ៅការ ពីការឈូសឆាយដីព្រៃឲ្យបានច្បាស់លាស់។
- សូមឲ្យក្រុមហ៊ុនអនុវត្តដំណើការរបស់ខ្លួនតាមផែនការមេ និងកិច្ចសន្យាដែលបានធ្វើជាមួយរដ្ឋាភិបាល

Draft

- សូមឲ្យក្រុមហ៊ុនផ្ដល់ជាអាហារូបករណ៍ ដល់មន្ត្រីបេស់មន្ទីរការងារ ដើម្បីបានបន្តការសិក្សានៅប្រទេសចិន អីពីច្បាប់ ឬផ្នែកកសិកម្មជាដើម
- សូមឲ្យក្រុមហ៊ុនបន្តក្នុងការបញ្ជូនកម្មករ ទៅរៀនពីបច្ចេកទេសថ្មីៗពីបរទេស។
- សូមឲ្យខាងក្រុមហ៊ុនជួយថែរក្សាការពារព្រៃឈើរក្សាទុកដែលមានដូចជា ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងព្រៃការពារតាមទ្រនាប់ដងអូរ។